ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



ក្រសួងអប់រំ យុវជន និងកីឡា



សេចក្តីព្រាង

ឯកសារជំនួយ
ការបង្រៀននិងរៀនភាសាអង់គ្លេស
ថ្នាក់ទី៥

ជាយកជ្ជាជអភិវឌ្ឍកម្មវិធីសិក្សា

២០១៦

អារម្ភកថា

ធនធានមនុស្សជាកម្លាំងចលករមួយចាំបាច់បំផុតក្នុងការអភិវឌ្ឍប្រទេសជាតិ។ គោលដៅសាលារៀនចំណេះទូទៅគឺ ការកសាងធនធានមនុស្សឱ្យក្លាយជាពលរដ្ឋពេញលេញ ដែលប្រកបដោយចំណេះដឹង សីលធម៌ និងជំនាញ។ ដើម្បីសម្រេចគោលដៅនេះ ក្រសួងអប់រំ យុវជន និងកីឡា បានអភិវឌ្ឍសៀវភៅគោលភាសាអង់គ្លេសជាបន្តបន្ទាប់ព្រមជាមួយនឹងឯកសារណែនាំការបង្រៀនភាសាអង់គ្លេសតាមកម្រិតថ្នាក់នីមួយៗ ដើម្បីជាជំនួយដល់ការបង្រៀន និងរៀនឱ្យបានសមស្រប និងឯកភាពគ្នា។

គណៈកម្មការនិពន្ធសៀវភៅភាសាអង់គ្លេសនៃក្រសួងអប់រំ យុវជន និងកីឡា បានរៀបរៀងឯកសារនេះឡើងស្របទៅនឹងខ្លឹមសារនៃសៀវភៅសិក្សាគោលភាសាអង់គ្លេសថ្នាក់ទី៥ ដែលរួមមាន៦ជំពូក និង៣៤មេរៀន ដើម្បីជាជំនួយដល់លោកគ្រូ អ្នកគ្រូ ក្នុងការបង្រៀនភាសាអង់គ្លេសនៅកម្រិតបឋមសិក្សា។

ឯកសារនេះ ត្រូវបានរៀបរៀងឡើងជាភាសាខ្មែរ និងមានឧទាហរណ៍មួយចំនួន ព្រមទាំងចម្លើយរបស់សំណួរនីមួយៗនៃសំណួរនៅក្នុងមេរៀននីមួយៗ ក្នុងន័យផ្តល់ភាពងាយស្រួលសម្រាប់លោកគ្រូ អ្នកគ្រូក្នុងការបង្រៀន ជាពិសេសលោកគ្រូ អ្នកគ្រូ ដែលមិនមែនឯកទេសភាសាអង់គ្លេស។

គណៈកម្មការភាសាអង់គ្លេសយើងខ្ញុំសង្ឃឹមថា លោកគ្រូ អ្នកគ្រូនឹងប្រើប្រាស់ឯកសារណែនាំនេះ ជាឯកសារជំនួយស្មារតីក្នុងការបង្រៀន និងរៀន ដើម្បីអភិវឌ្ឍចំណេះដឹង បំណិនទាំងបួនគឺ និយាយ អាន ស្តាប់ និងសរសេរដោយផ្តោតជាសំខាន់លើបំណិនទំនាក់ទំនងមូលដ្ឋានក្នុងនិយាយភាសាអង់គ្លេស ដែលជាមូលដ្ឋានគ្រឹះក្នុងការពង្រឹងសមត្ថភាពរបស់សិស្សដើម្បីបន្តទៅថ្នាក់បន្តបន្ទាប់ទៀត។

គណៈកម្មការនិពន្ធសៀវភៅភាសាអង់គ្លេសយើងខ្ញុំ រីករាយរង់ចាំទទួលនូវមតិយោបល់ស្ថាបនាពីលោកគ្រូ អ្នកគ្រូ និងអ្នកមានចំណាប់អារម្មណ៍ទាំងអស់ ដើម្បីកែលម្អឯកសារនេះឱ្យកាន់តែប្រសើរឡើងថែមទៀត។

គណៈកម្មការនិពន្ធ

គណៈកម្មការ
អភិវឌ្ឍឯកសារជំនួយការរៀននិងបង្រៀនភាសាអង់គ្លេសថ្នាក់ទី៤

គណៈកម្មការគ្រប់គ្រង

ឯកឧត្តម បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

ឯកឧត្តម **ណាត ប៊ុនរឿន** ឯកឧត្តម **អ៊ឹម ភុច**

លោកជំទាវ **ឧត់ សារ៉ឹម**

គណៈកម្មការត្រួតពិនិត្យ

ឯកឧត្តម **ពុត សាមិត** ឯកឧត្តម **ឡោ ឆវណ្ណា**

លោក **ង៉ា ភុទ្ធី** លោក **យិន ធី**

គណៈកម្មការរៀបចំ

លោក **អាំ សុបុល** លោក **ឡេង សារី**

លោក **ម៉ិញ សុតា** លោក **ទឹម ឥន**

លោកស្រី **កែវ រដ្ឋា** លោកស្រី **ឧច ពេជ្រឥរី**

គណៈកម្មការអនុម័ត

លោកជំទាវ **ឧត់ សារ៉ឹម** ឯកឧត្តម **ឡោ ឆវណ្ណា**

លោក **យិន ធី** លោក **លឹម សុត្ថារិទ្ធ**

មាតិកា

អារម្ភកថា .....

គណៈកម្មការ .....

មាតិកា .....

សេចក្តីណែនាំ .....

Chapter 1: Shops and Shopping (ជំពូកទី១៖ ហាងលក់ទំនិញ និងការទិញឥវ៉ាន់).....5

Unit 1: Selling Food (មេរៀនទី១៖ ការលក់ម្ហូបអាហារ) 5

Unit 2: Selling Fruits (មេរៀនទី២៖ ការលក់ផ្លែឈើ) 7

Unit 3: Selling Things By The Road (មេរៀនទី៣៖ ការលក់របស់របរតាមផ្លូវ) 9

Unit 4: Shopping (មេរៀនទី៤៖ ការទិញឥវ៉ាន់) 11

Unit 5: Review (មេរៀនទី៥៖ រំលឹកមេរៀនឡើងវិញ) 13

Chapter 2: Farms and Farming (ជំពូកទី២៖ កសិដ្ឋាន និងរបរកសិកម្ម) 15

Unit 1: Working On The Farm (មេរៀនទី១៖ ធ្វើការក្នុងកសិដ្ឋាន) 15

Unit 2: Animals On The Farm (មេរៀនទី២៖ សត្វក្នុងកសិដ្ឋាន) 17

Unit 3: Farming (មេរៀនទី៣៖ របរកសិកម្ម) 19

Unit 4: At A Market (មេរៀនទី៤៖ នៅផ្សារ) 21

Unit 5: Review (មេរៀនទី៥៖ រំលឹកមេរៀនឡើងវិញ) 23

Chapter 3: School And Family (ជំពូកទី៣៖ សាលារៀន និងគ្រួសារ).....25

Unit 1: Family Memmbers (មេរៀនទី១៖ សមាជិកគ្រួសារ) 25

Unit 2: Going To School (មេរៀនទី២៖ ទៅសាលារៀន) 28

Unit 3: School (មេរៀនទី៣៖ សាលារៀន).....30

Unit 4: Family Holydays (មេរៀនទី៤៖ ដំណើរកំសាន្តក្នុងគ្រួសារ).....32

Unit 5: In The Morning (មេរៀនទី៥៖ នៅពេលព្រឹក) 35

Unit 6: Review (មេរៀនទី៦៖ រំលឹកមេរៀនឡើងវិញ) 37

Chapter 4: Buying (ជំពូកទី៤៖ ការទិញ).....39

Unit 1: Buying Fruits (មេរៀនទី១៖ ការទិញផ្លែឈើ) 39

Unit 2: The Sport Shop (មេរៀនទី២៖ ហាងលក់សម្ភារៈកីឡា) 41

Unit 3: Buying Food (មេរៀនទី៣៖ ការទិញម្ហូបអាហារ).....43

Unit 4: Number 11-19 (មេរៀនទី៤៖ ចំនួនពី១១ ដល់១៩).....45

Unit 5: Number 20-99 (មេរៀនទី៥៖ ចំនួនពី២០ ដល់៩៩) 47

Unit 6: Hundred (មេរៀនទី៦៖ ខ្ទង់រយ).....49

Unit 7: Thousand (មេរៀនទី៧៖ ខ្ទង់ពាន់) 51
Unit 8: Review (មេរៀនទី៨៖ រំលឹកមេរៀនឡើងវិញ) 53

Chapter 5: Magic ‘e’ (ជំពូកទី៥៖ ការបំផ្លែងសូរ ‘e’) 55
Unit 1: Magic ‘e’ Sound ‘a’ (មេរៀនទី១៖ ការបំផ្លែងសូរ ‘e’ សម្លេង ‘a’) 55
Unit 2: Magic ‘e’ Sound ‘i’ (មេរៀនទី២៖ ការបំផ្លែងសូរ ‘e’ សម្លេង ‘i’) 58
Unit 3: Magic ‘e’ Sound ‘o’ (មេរៀនទី៣៖ ការបំផ្លែងសូរ ‘e’ សម្លេង ‘o’) 60
Unit 4: Magic ‘e’ Sound ‘u’ (មេរៀនទី៤៖ ការបំផ្លែងសូរ ‘e’ សម្លេង ‘u’) 62
Unit 5: Review (មេរៀនទី៦៖ រំលឹកមេរៀនឡើងវិញ) 64

Chapter 6: School And Family (ជំពូកទី៦៖ អាកាសធាតុ) 65
Unit 1: Weather’s Today (មេរៀនទី១៖ អាកាសធាតុថ្ងៃនេះ) 65
Unit 2: The Rainy Season (មេរៀនទី២៖ រដូវវស្សា) 68
Unit 3: The Dry Season (មេរៀនទី៣៖ រដូវប្រាំង) 70
Unit 4: The Flood (មេរៀនទី៤៖ ទឹកជំនន់) 72
Unit 5: Review (មេរៀនទី៦៖ រំលឹកមេរៀនឡើងវិញ) 74

សេចក្តីណែនាំ
ការរៀននិងបង្រៀនភាសាអង់គ្លេស

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសក្នុងកម្មវិធីសិក្សានៅកម្រិតបឋមសិក្សាចំណេះទូទៅពីថ្នាក់ទី៤ដល់ថ្នាក់ទី៦ ដើម្បីផ្តល់ឱកាសឱ្យសិស្សបានសិក្សាជាមូលដ្ឋានដំបូងនៃភាសាអង់គ្លេសសម្រាប់ជាគ្រឹះក្នុងការបន្តការសិក្សានៅកម្រិតមធ្យមសិក្សា។ ដូច្នេះ សាលារៀននីមួយៗត្រូវអនុវត្តកម្មវិធីសិក្សានិងសៀវភៅសិក្សាគោលភាសាអង់គ្លេសមានប្រសិទ្ធភាព ដូចខាងក្រោម៖

១. ការប្រើប្រាស់សៀវភៅភាសាអង់គ្លេស

គ្រប់គ្រឹះស្ថានសិក្សាបឋមសិក្សាចំណេះទូទៅសាធារណៈទាំងអស់ ត្រូវប្រើប្រាស់សៀវភៅ English Grade 5 ជាសៀវភៅសិក្សាគោលតែមួយគត់ក្នុងការបង្រៀននិងរៀននៅតាមសាលាបឋមសិក្សាទូទាំងប្រទេស។

២. ការប្រើប្រាស់ម៉ោងសិក្សា

២.១. ការបង្រៀននិងរៀនភាសាអង់គ្លេស ត្រូវបែងចែករបាយម៉ោងឱ្យបានច្បាស់លាស់ក្នុងកាលវិភាគប្រចាំសប្តាហ៍ ដោយអនុវត្តទៅតាមការកំណត់ក្នុងក្របខណ្ឌកម្មវិធីសិក្សា និងកម្មវិធីសិក្សា ០២ម៉ោងសិក្សាក្នុងមួយសប្តាហ៍ ត្រូវនឹង ៣៥សប្តាហ៍ក្នុងមួយឆ្នាំ ហើយ០១ម៉ោងសិក្សាមានរយៈពេល៤០នាទី ដូច្នេះ៖

- សរុបម៉ោងកំណត់ : ២ម៉ x ៣៥សប្តាហ៍ = ៧០ ម៉ោងសិក្សាក្នុងមួយឆ្នាំ
- សរុបម៉ោងបង្រៀន : = ៥៦ ម៉ោងសិក្សាក្នុងមួយឆ្នាំ
- សរុបម៉ោងសល់ : = ១៤ ម៉ោងសិក្សាក្នុងមួយឆ្នាំ ម៉ោងដែលនៅសល់ គ្រូអាចរំលឹកមេរៀនសារឡើងវិញ ឬធ្វើលំហាត់បន្ថែម។

២.២. ប្រធានកម្រងត្រូវសហការជាមួយនាយកសាលារៀនដើម្បីកំណត់ម៉ោងក្នុងកាលវិភាគច្បាស់លាស់ឱ្យគ្រប់សាលាបឋមសិក្សាអនុវត្តការបង្រៀននិងរៀនភាសាអង់គ្លេសបានឯកភាពគ្នា។

៣. ការប្រើប្រាស់ធនធានគ្រូបង្រៀន

៣.១. នាយកសាលារៀនចាត់តាំងគ្រូបង្រៀនដែលមានចំណេះដឹងផ្នែកភាសាអង់គ្លេស ឬធ្លាប់បានចូលរួមក្នុងវគ្គតម្រង់ទិសការប្រើប្រាស់កម្មវិធីសិក្សានិងសៀវភៅសិក្សាគោល និងវិធីសាស្ត្របង្រៀនភាសាអង់គ្លេសពីថ្នាក់ទី៤ដល់ថ្នាក់ទី៦ ជាគ្រូបង្គោលសម្រាប់បង្រៀនទាំងបីកម្រិតថ្នាក់។ ចំពោះម៉ោងដែលគ្រូបង្រៀននោះនៅសេសសល់ ត្រូវជួយការងាររដ្ឋបាល ឬបណ្ណាល័យសាលារៀន

៣.២. សាលារៀនដែលពុំទាន់ឆ្លងកាត់វគ្គតម្រង់ទិសការប្រើប្រាស់កម្មវិធីសិក្សានិងសៀវភៅសិក្សាគោល និងវិធីសាស្ត្របង្រៀនភាសាអង់គ្លេសពីថ្នាក់ទី៤ដល់ថ្នាក់ទី៦ គណៈគ្រប់គ្រងសាលារៀន ត្រូវជ្រើសរើសយកគ្រូបង្រៀនដែលចេះភាសាអង់គ្លេសសម្រាប់បង្រៀនមុខវិជ្ជាភាសាអង់គ្លេសពីថ្នាក់ទី៤ដល់ទី៦ ហើយសមាសភាពគ្រូទាំងនោះ ជាមុខសញ្ញាក្នុងការទទួលការបណ្តុះបណ្តាលជំនាញ ឬបំប៉នសមត្ថភាពផ្នែកកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល និងវិធីសាស្ត្របង្រៀនភាសាអង់គ្លេសនៅពេលអនាគត។

៤. ការកំណត់ពិន្ទុ

ការដាក់ពិន្ទុ ត្រូវធ្វើការវាយតម្លៃទៅលើសមាសភាគទាំងបួននៃភាសាអង់គ្លេស គឺ ការស្តាប់ ការនិយាយ ការអាន និងការសរសេរ ដែលពិន្ទុសរុបស្មើនឹង ១០ពិន្ទុ ដូចមុខវិជ្ជាដទៃទៀតដែរ។

៥. **វិធីសាស្ត្របង្រៀន**

.....

កម្មវិធីសាលាកុមារមេត្រី ទាមទារឱ្យគ្រូចេះលើកទឹកចិត្តសិស្សដោយការសរសើរ ឬផ្តល់រង្វាន់ មិនត្រូវធ្វើឥរិយាបថណាដែលនាំឱ្យសិស្សខ្លាចមិនហ៊ានចូលរួម មិនហ៊ាននិយាយ ត្រូវជួយសិស្សឱ្យមានសង្ឃឹម ហ៊ានសួរ ហ៊ានឆ្លើយ និងបង្កឱ្យមានបរិយាកាសសប្បាយរីករាយជាប្រចាំ។

៦. **ការប្រើប្រាស់សម្ភារៈ**

៧. **ការវាយតម្លៃ**

៨. **លំនាំបង្រៀន**

៨.១. ការបង្រៀនអានពាក្យ៖

៨.២. ការបង្រៀនអានអត្ថបទ៖

៨.៣. ការបង្រៀនសរសេរតាមអាន៖

៨.៤. ការបង្រៀនសន្ធនា៖

៨.៥. ការបង្រៀនតែងល្បះតាមរូបភាព៖

៨.៦. ការបង្រៀននិយាយ៖

៨.៧. ការលេងល្បែងសិក្សា៖ គ្រូអាចមានការរៀបចំជារចនាសម្ព័ន្ធ ដើម្បីឱ្យសិស្សមានភាពសកម្ម អាចចូលរួមជាដៃគូ ជាក្រុម ជាប្រព័ន្ធ អាចមានការប្រកួតប្រជែងដោយកំណត់ពេលវេលាជាក់លាក់ ហើយគ្រូក៏ផ្តល់នូវការកំសាន្ត និងភាពសប្បាយរីករាយ ដើម្បីពង្រឹងនូវខ្លឹមសារមេរៀនដែលបានរៀនរួម។

ជំពូកទី១

CHAPTER 1

ហាងលក់ទំនិញ និងការដើរទិញឥវ៉ាន់

Shops and Shopping

មេរៀនទី១ៈ ការលក់អ្នកបអាហារ

Unit 1: Selling Food

រយៈពេល ២ ម៉ោង

១. ឥតុបំណង (Objective)

- អានពាក្យ fish, garlic, honey, ice cream និង jam ជាមួយគ្រូ
- សរសេរពាក្យ fish, garlic, honey, ice cream និង jam ដោយបង្ហាញរូបភាពដែលត្រូវនឹងពាក្យនោះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ fish, garlic, honey, ice cream និង jam។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ fish, garlic, honey, ice cream និង jam
- ខ្សែអាត់សម្លេង CD ឬ DVD។

៣. លំនាំបង្រៀន (Teaching Process)

A. រៀនពាក្យ (Vocabulary)

ចូរមើលរូបភាព។ ស្តាប់ និងថាតាម។ Look at the pictures. Listen and repeat.

គ្រូ : - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់នៅលើក្តារខៀន រួចអានឱ្យសិស្សស្តាប់ បន្ទាប់ឱ្យសិស្សថាតាម។ បកប្រែពាក្យជាភាសាខ្មែរ fish = ត្រី, garlic = ខ្ទឹមស, honey = ទឹកឃ្មុំ, ice cream = ការ៉េម និង jam = ដំណាប់។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក។ Spell each word in the box with your partner.

គ្រូ : - ឱ្យសិស្សម្តងពីរនាក់ៗប្រកបពាក្យ។

ឧទាហរណ៍ ៖ សិស្សម្នាក់ (A) និយាយថា Please spell the word fish។ រួចសិស្សម្នាក់ទៀត (B) ថា fish I spell f-i-s-h។

C. អំណាន (Reading)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានអត្ថបទឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សអានតាម
- ពន្យល់ពាក្យពិបាកៗ ឬពាក្យថ្មី
- ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ។

២. ចូរសួរ និងឆ្លើយសំណួរ។ Ask and answer the questions.

គ្រូ : ឱ្យសិស្សអានអត្ថបទស្ងាត់ៗរៀងៗខ្លួន បន្ទាប់មកឆ្លើយនឹងសំណួរ។ *ឧទាហរណ៍៖*

Questions 1: What does she sell in her shop?

Answers: - She sells fish.
- She sells garlic

Questions 2: What does he sell in his shop?

Answers: - He sells honey.
- He sells ice cream.
- He sells jam.

D. ការសន្ទនា (Conversation)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានសន្ទនាឱ្យសិស្សស្តាប់
- ឱ្យសិស្សពីរនាក់ម្តងៗសន្ទនាគ្នា។ ឧទាហរណ៍ :

Ms. Linda: Can I help you?
Ratha : Yes, I want to buy three fish, please.

២. ចូរអនុវត្តជាមួយដៃគូរបស់អ្នក។ Practice with your partner.

គ្រូ : សិស្សសន្ទនាជាមួយដៃគូដោយប្រើពាក្យឱ្យបានត្រឹមត្រូវ។

ឧទាហរណ៍ ៖ A: Can I help you?

ចម្លើយ ៖ B. Three និង fish. A. Else. B. thanks។

E. សំណេរ (Writing)

ចូរសរសេរពាក្យដែលខ្វះដាក់ក្នុងសៀវភៅសរសេររបស់អ្នក។ Write the missing words in your notebook.

ឧទាហរណ៍ ៖ (1) **shops**.

ចម្លើយ៖ (2). fish, (3). garlic, (4). Sells, (5). ice cream, (6). honey។

គួរចងចាំ (Remember)

គ្រូ : - បញ្ជាក់ប្រាប់សិស្សឱ្យចងចាំពាក្យ fish, garlic, honey, ice cream និង jam។
- ប្រាប់ឱ្យសិស្សចងចាំពីរបៀបបង្កើតទម្រង់សួរជាមួយ What does he/she sell in his/her shop? និងទម្រង់ឆ្លើយ He/she sells fish / garlic / honey / ice cream / jam។

មេរៀនទី២ : ការលក់ផ្លែឈើ

Unit 2: Selling Fruits

រយៈពេល ២ ម៉ោង

១. គន្លឹះបំណង (Objective)

- អានពាក្យ lemons, mangos, nuts និង oranges ជាមួយនឹងគ្រូ
- សរសេរពាក្យ lemons, mangos, nuts និង oranges ដោយបង្ហាញ រូបភាពដែលត្រូវ នឹងពាក្យនោះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ lemon, mango, nut និង orange ។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ lemon, mango, nut និង orange
- ខ្សែអាត់សម្លេង CD ឬ DVD ។

៣. ជំនាំបង្រៀន (Teaching Process)

A. រៀនពាក្យ (Vocabulary)

ចូរមើលរូបភាព ។ ស្តាប់ និងថាតាម ។ Look at the pictures. Listen and repeat.

គ្រូ : - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់នៅលើក្តារខៀន រួចអានឱ្យសិស្សស្តាប់ បន្ទាប់ឱ្យសិស្សថាតាម ។

- បកប្រែពាក្យជាភាសាខ្មែរ lemon = ក្រូចឆ្មារ, mango = ផ្លែ ស្វាយ, nut = គ្រាប់ធញ្ញជាតិ និង orange = ក្រូចពោធិ៍សាត់ ។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក ។ Spell each word in the box with your partner.

គ្រូ : - ឱ្យសិស្សម្តងពីរនាក់ៗប្រកបពាក្យ ។

- *ឧទាហរណ៍ ៖* សិស្សម្នាក់ (A) និយាយថា Please spell the word lemon. ហើយសិស្សម្នាក់ទៀត (B) ថា lemon I spell l-e-m-o-n.

C. អំណាន (Reading)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក ។ Listen to your teacher and repeat.

គ្រូ : - អានអត្ថបទឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សអានតាម

- ពន្យល់ពាក្យពិបាកៗ ឬពាក្យថ្មី
- ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ ។

២. ចូរសួរ និងឆ្លើយសំណួរ ។ Ask and answer the questions.

គ្រូ : ឱ្យសិស្សអានអត្ថបទស្ងាត់ៗរៀងៗខ្លួនបន្ទាប់ឆ្លើយនឹងសំណួរ ។ *ឧទាហរណ៍ ៖*

Questions: What does she sell in her shop?

Answers: - She sells lemons.

- She sells mangos.
- She sells nuts.
- She sells oranges.

D. ការសន្ទនា (Conversation)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានសន្ទនាឱ្យសិស្សស្តាប់

- ឱ្យសិស្សពីរនាក់ម្តងៗសន្ទនាគ្នា។ *ឧទាហរណ៍៖*

Ms. Kim: Can I help you?

Rithy : Yes, I want to buy mangos, please.

២. ចូរអនុវត្តជាមួយដៃគូរបស់អ្នក។ Practice with your partner.

គ្រូ : ឱ្យសិស្សសន្ទនាជាមួយដៃគូដោយប្រើពាក្យឱ្យបានត្រឹមត្រូវ។ *ឧទាហរណ៍៖* A: Can I help you?

ចម្លើយ ៖ B. mangos A. else B. nuts។

E. សំណេរ (Writing)

ចូរសរសេរពាក្យដែលខ្វះដាក់ក្នុងសៀវភៅសរសេររបស់អ្នក។ Write the missing words in your notebook.

ឧទាហរណ៍ ៖ (1) market.

ចម្លើយ៖ (2).fruits (3). lemons (4). oranges (5). nuts។

គួរចងចាំ (Remember)

គ្រូ : - បញ្ជាក់ប្រាប់សិស្សឱ្យចងចាំពាក្យ lemons, mangos, nuts និង oranges។

- ប្រាប់ឱ្យសិស្សចងចាំពីរបៀបបង្កើតទម្រង់សួរជាមួយ What does she sell in her shop? និងទម្រង់ឆ្លើយ She sells lemons / mangos / nuts / oranges។

មេរៀនទី៣ : ការលក់របស់របរតាមផ្លូវ
Unit 3: Selling Things By The Road

រយៈពេល ២ ម៉ោង

១. គោលបំណង (Objective)

- អានពាក្យ pineapple, quail, rice, sugar និង tea ជាមួយនឹងគ្រូ
- សរសេរពាក្យ pineapple, quail, rice, sugar និង tea ដោយបង្ហាញ រូបភាពដែលត្រូវនឹងពាក្យនោះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ pineapple, quail, rice, sugar និង tea។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ pineapple, quail, rice, sugar និង tea
- ខ្សែអាត់សម្លេង CD ឬ DVD។

៣. ជំហាំបង្រៀន (Teaching Process)

A. រៀនពាក្យ (Vocabulary)

ចូរមើលរូបភាព។ ស្តាប់ និងថាតាម។ Look at the pictures. Listen and repeat.

គ្រូ : - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់នៅលើក្តារខៀន រួចអានឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សថាតាម។

- បកប្រែពាក្យជាភាសាខ្មែរ pineapple = ផ្លែម្នាស់, quail = សត្វក្រួច, rice = ស្រូវ អង្ករ, sugar = ស្ករ និង tea = តែ។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក។ Spell each word in the box with your partner.

គ្រូ : - ឱ្យសិស្សម្តងពីរនាក់ៗប្រកបពាក្យ។

- *ឧទាហរណ៍៖* សិស្សម្នាក់ (A) និយាយថា Please spell the word **pineapple**. និងម្នាក់ទៀត (B) ថា pineapple I spell p-i-n-e-a-p-p-l-e.

C. អំណាន (Reading)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានអត្ថបទឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សអានតាម

- ពន្យល់ពាក្យពិបាកៗ ឬពាក្យថ្មី

- ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ។

២. ចូរសួរ និងឆ្លើយសំណួរ។ Ask and answer the questions.

គ្រូ : - ឱ្យសិស្សអានអត្ថបទស្ងាត់ៗរៀងៗខ្លួន បន្ទាប់មកឆ្លើយនឹងសំណួរ។ *ឧទាហរណ៍* ៖

What do Mr. Sovan and Ms. Sokha sell?

They sell pineapples / quails / rice / sugar / tea.

D. ការសន្ទនា (Conversation)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានសន្ទនាឱ្យសិស្សស្តាប់

- ឱ្យសិស្សពីរនាក់ម្តងៗសន្ទនាគ្នា។ *ឧទាហរណ៍៖*

Ms. Sokha: Hello. Can I help you?

Borey : Yes, I want to buy quail and rice, please.

២. ចូរអនុវត្តជាមួយដៃគូរបស់អ្នក។ Practice with your partner.

គ្រូ : - ឱ្យសិស្សសន្ទនាជាមួយដៃគូដោយប្រើពាក្យឱ្យបានត្រឹមត្រូវ។

- *ឧទាហរណ៍៖* A: Can I help you?

- *ចម្លើយ៖* B. quail និង rice A. you A. do B. sugar និង tea។

E. សំណេរ (Writing)

ចូរសរសេរពាក្យដែលខ្វះដាក់ក្នុងសៀវភៅសរសេររបស់អ្នក។ Write the missing words in your notebook.

ឧទាហរណ៍៖ (1) many.

ចម្លើយ៖ (2).pineapple (3).rice (4).tea (5). start។

គួរចងចាំ (Remember)

គ្រូ : - បញ្ជាក់ប្រាប់សិស្សឱ្យចងចាំពាក្យ pineapple, quail, rice, sugar និង tea។

- ប្រាប់ឱ្យសិស្សចងចាំពីរបៀបបង្កើតទម្រង់សួរជាមួយ What do Mr. Sovan and Ms. Sokha sell? និងទម្រង់ឆ្លើយ They sell pineapple / quail / rice / sugar / tea។

មេរៀនទី៤ : ការដើរទិញឥវ៉ាន់

Unit 4: Shopping

រយៈពេល ២ ម៉ោង

១. គោលបំណង (Objective)

- អានពាក្យ umbrella, vegetables, watermelon និង zip ជាមួយនឹងគ្រូ
- សរសេរពាក្យ umbrella, vegetables, watermelon និង zip ដោយបង្ហាញរូបភាពដែលត្រូវនឹងពាក្យនោះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ umbrella, vegetable, watermelon និង zip ។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ umbrella, vegetables, watermelon និង zip
- ខ្សែអាត់សម្លេង CD ឬ VCD ។

៣. ជំនាំបង្រៀន (Teaching Process)

A. រៀនពាក្យ (Vocabulary)

ចូរមើលរូបភាព ។ ស្តាប់ និងថាតាម ។ Look at the pictures. Listen and repeat.

គ្រូ : - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់នៅលើក្តារខៀន រួចអានឱ្យ សិស្សស្តាប់ បន្ទាប់ឱ្យ សិស្សថាតាម ។

- បកប្រែពាក្យជាភាសាខ្មែរ umbrella = ឆត្រ, vegetable = បន្លែ, watermelon = ផ្លែឪឡឹក និង zip = ខ្សែរួត ។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក ។ Spell each word in the box with your partner.

គ្រូ : - ឱ្យសិស្សម្តងពីរនាក់ៗប្រកបពាក្យ ។

- *ឧទាហរណ៍ៈ* សិស្សម្នាក់ (A) និយាយថា Please spell the word umbrella ហើយម្នាក់ទៀត (B) ថា umbrella I spell u-m-b-r-e-l-l-a.

C. អំណាន (Reading)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក ។ Listen to your teacher and repeat.

គ្រូ : - អានអត្ថបទឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សអានតាម

- ពន្យល់ពាក្យពិបាកៗ ឬពាក្យថ្មី

- ឱ្យសិស្សម្នាក់អានអត្ថបទនិងម្នាក់ទៀតបកប្រែជាភាសាខ្មែរ ។

២. ចូរសួរ និងឆ្លើយសំណួរ ។ Ask and answer the questions.

គ្រូ : - ឱ្យសិស្សអានអត្ថបទស្ងាត់ៗរៀងៗខ្លួន បន្ទាប់មកឆ្លើយនឹងសំណួរ ។

- *ឧទាហរណ៍ៈ* What do they want to buy?

- Their mother wants to buy vegetables.
- Their mother wants to buy watermelon.
- Vanna wants to buy umbrella.
- Darith wants to buy zip.
- Their mother wants to buy oranges.

D. ការសន្ទនា (Conversation)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានសន្ទនាឱ្យសិស្សស្តាប់

- ឱ្យសិស្សពីរនាក់ម្តងៗសន្ទនាគ្នា។
- *ឧទាហរណ៍៖*

Seller: Good morning. Can I help you?
Vibol: Yes, I want to buy something.

២. ចូរអនុវត្តជាមួយដៃគូរបស់អ្នក។ Practice with your partner.

គ្រូ : - ឱ្យសិស្សសន្ទនាជាមួយដៃគូដោយប្រើពាក្យឱ្យបានត្រឹមត្រូវ។

- *ឧទាហរណ៍៖* A: Good morning. Can I help you?
- ចម្លើយ៖ B. buy A. do B. watermelons
  A. watermelons B. want និង can A. buy B. you ។

E. សំណេរ (Writing)

ចូរសរសេរពាក្យដែលខ្វះដាក់ក្នុងសៀវភៅសរសេររបស់អ្នក។ Write the missing words in your notebook.

ឧទាហរណ៍៖ (1) mother.

ចម្លើយ៖ (2) vegetables, (3) watermelons, (4) umbrella, (5) zip

គួរចងចាំ (Remember)

គ្រូ : - បញ្ជាក់ប្រាប់សិស្សឱ្យចងចាំពាក្យ umbrella, vegetables, watermelon និង zip។

- ប្រាប់ឱ្យសិស្សចងចាំពីរបៀបបង្កើតទម្រង់សួរជាមួយ What do they want to buy? និងទម្រង់ឆ្លើយ They want to buy umbrella / vegetables / watermelons / oranges / zip។

មេរៀនទី៥ : រំលឹកមេរៀនឡើងវិញ

Unit 5: Review

រយៈពេល ២ ម៉ោង

១. វត្ថុបំណង (Objective)

- អានពាក្យដែលមាននៅក្នុងប្រអប់ជាមួយនឹងគ្រូ
- បង្ហាញពីរបៀបបង្កើតប្រយោគសួរ និងប្រយោគស្រប ដើម្បីឱ្យសិស្សអនុវត្ត
- បង្ហាញរូបភាពដើម្បីឱ្យសិស្សមើលរូប ហើយឆ្លើយពាក្យឱ្យត្រូវតាមរូបភាពនីមួយៗ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ fish, garlic, honey, ice cream, jam, vegetable, quail, lemon, mango, watermelon, pineapple, rice, sugar, tea, umbrella, zip, nut និងចេះឆ្លើយពាក្យឱ្យត្រូវតាមរូបភាពនីមួយៗ។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ oranges, mangos, watermelons, pineapples, fish, jam, quail, garlics, nuts, rice, tea និង vegetables
- ខ្សែអាត់សម្លេង CD ឬ VCD។

៣. ជំនាំបង្រៀន (Teaching process)

A. វេយ្យាករណ៍ (Language Focus)

គ្រូ : - ឱ្យសិស្សបង្កើតប្រយោគសួរ និងប្រយោគឆ្លើយ បន្ទាប់មកឱ្យមកសិស្សអនុវត្តជាមួយដៃគូ ដោយម្នាក់ជាអ្នកសួរ និងម្នាក់ទៀតជាអ្នកឆ្លើយ។

- What does she/he sell in her/his shop?
  She/he sells honey and jam.
- What do they sell by the road?
  They sell rice, sugar and tea.
- Can I help you?
  Yes, I want to buy fish.
- How many kilograms of fish do you want to buy?
  I want to buy three kilograms of fish.

B. ស្តាប់ និងនិយាយ

១. ចូរប្រកបពាក្យនៅក្នុងប្រអប់។ Spell the words in the box.

គ្រូ : - ឱ្យសិស្សពីរនាក់ម្តងៗដើម្បីប្រកបពាក្យ។

- *ឧទាហរណ៍៖* សិស្សម្នាក់ (A) និយាយថា Please spell the word fish. ហើយសិស្សម្នាក់ទៀត (B) ថា fish I spell f-i-s-h។

២. ចូរមើលរូបភាព។

ចូរឆ្លើយពាក្យឱ្យត្រូវតាមរូបភាពនីមួយៗ។ Look at the pictures. Read the word of each picture.

គ្រូ : - ឱ្យសិស្សលើករូបភាពម្តងមួយៗ រីឯសិស្សដទៃអាចឆ្លើយពាក្យឱ្យត្រូវទៅតាមរូបនីមួយៗ។

- *ឧទាហរណ៍៖* រូបផ្លែក្រូច សិស្សត្រូវឆ្លើយថា oranges។
- ចម្លើយតាមលំដាប់រូបភាព៖ mangos, watermelons, pineapples, fish, jam, quail, garlics, nuts, rice, tea និង vegetables។

C. ការនិយាយ (Speaking)

ចូរមើលរូបភាព។ សួរ និងឆ្លើយសំណួរជាមួយដៃគូរបស់អ្នក។ Look at the pictures. Ask and answer the questions with your partner.

គ្រូ : - ឱ្យសិស្សសន្ទនាជាមួយដៃគូដោយប្រើពាក្យឱ្យបានត្រឹមត្រូវ។

- ចម្លើយ៖ B. ice cream, B. tea, honey, B. oranges។

D. ការសរសេរ (Writing)

ចូរសរសេរពាក្យតាមរូបភាពនីមួយៗក្នុងសៀវភៅសរសេររបស់អ្នក។ Write the word of each picture in your notebook.

គ្រូ : - បង្ហាញរូបភាពដល់សិស្ស ដើម្បីបំពេញពាក្យដែលត្រូវនឹងរូបភាពទាំងនោះ។

- ចម្លើយតាមលំដាប់លំដោយរូបភាព៖ (1) fish; (2) sugar; (3) garlics; (4) umbrella; (5) lemons; (6) vegetables; (7) oranges; (8) watermelons; (9) pineapples; (10) zip។

ជំពូកទី២

CHAPTER 2

កសិដ្ឋាន និងបរកសិកម្ម

Farms And Farming

មេរៀនទី១ ធ្វើការក្នុងកសិដ្ឋាន

Unit 1: Working On The Farm

រយៈពេល ២ ម៉ោង

១. ឥតុបំណង (Objective)

- អានពាក្យ farm, hand, pond, sand និង sheep ជាមួយនឹងគ្រូ
- សរសេរពាក្យ farm, hand, pond, sand និង sheep ដោយបង្ហាញរូបភាពដែលត្រូវនឹងពាក្យនោះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ ការអានអត្ថបទខ្លីៗ ការសន្ទនា ការនិយាយ និងសំណេរពាក្យបំពេញចន្លោះខ្វះខាត។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ farm, hand, pond, sand និង sheep
- ហ្វឺត ឬដីស និងក្តារខៀន
- ខ្សែអាត់សម្លេង CD ឬ VCD។

៣. ជំនាំបង្រៀន (Teaching Process)

A. រៀនពាក្យ (Vocabulary)

ចូរមើលរូបភាព។ ស្តាប់ និងថាតាម។ Look at the pictures. Listen and repeat.

គ្រូ : - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់នៅលើក្តារខៀន រួចអានឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សថាតាម។

- បកប្រែពាក្យជាភាសាខ្មែរ farm = កសិដ្ឋាន, hand = ដៃ, pond = ស្រះទឹក, sand = ដីខ្សាច់ និង sheep = ចៀម។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក។ Spell each word in the box with your partner.

គ្រូ : - ឱ្យសិស្សពីរនាក់ម្តងៗដើម្បីប្រកបពាក្យ។

- *ឧទាហរណ៍៖* សិស្សម្នាក់ (A) និយាយថា Please spell the word farm. ហើយម្នាក់ទៀត (B) ថា farm I spell f-a-r-m។

C. អំណាន (Reading)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានអត្ថបទឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សអានតាម
- ពន្យល់ពាក្យពិបាកៗ ឬពាក្យថ្មី
- ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ។

២. ចូរសួរ និងឆ្លើយសំណួរ។ Ask and answer the questions.

គ្រូ : - ឱ្យសិស្សអានអត្ថបទស្ងាត់ៗរៀងៗខ្លួន បន្ទាប់មកចាប់ដៃគូសួរ និងឆ្លើយសំណួរ។
- *ឧទាហរណ៍ ៖* What is Ms. Dany? She is a farmer.
- ចម្លើយ ៖ 1. She feeds sheep, cows, chickens, oxen and fish.
2. On the farm, there are many fruit trees, fish, vegetables and animals.
3. In the pond, there are many fish.
4. Yes, she is.

D. ការសន្ទនា (Conversation)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានសន្ទនាឱ្យសិស្សស្តាប់
- ឱ្យសិស្សពីរនាក់ម្តងៗសន្ទនាគ្នា។
- *ឧទាហរណ៍ ៖* A: What does your farther do?
B: My father is a framer.

២. ចូរអនុវត្តជាមួយដៃគូរបស់អ្នក។ Practice with your partner.

គ្រូ : - ឱ្យសិស្សសន្ទនាជាមួយដៃគូដោយប្រើពាក្យឱ្យបានត្រឹមត្រូវ។
- *ឧទាហរណ៍ ៖* A: What does your father do?
- ចម្លើយ ៖ B. farmer, A. work, B. works, A. farm, B. are ។

E. សំណេរ (Writing)

ចូរសរសេរពាក្យដែលខ្វះដាក់ក្នុងសៀវភៅសរសេររបស់អ្នក។ Write the missing words in your notebook.

គ្រូ : - ឱ្យសិស្សសរសេរពាក្យក្នុងប្រអប់បំពេញនៅចន្លោះខ្វះខាត។
- *ឧទាហរណ៍ ៖* (1) farmer.
- ចម្លើយ : (2) sheep, (3) pond, (4) vegetables, (5) works ។

គួរចងចាំ (Remember)

គ្រូ : - បញ្ជាក់ប្រាប់សិស្សឱ្យចងចាំពាក្យ farm, hand, pond, sand និង sheep ។
- ប្រាប់ឱ្យសិស្សចងចាំពីពាក្យដែលមានព្យញ្ជនៈផ្សំ sh នៅពីមុខពាក្យ (sheep, shop) និង sh, nd នៅពីក្រោយពាក្យ (fish, hand, pond, sand) ។
- ប្រាប់ឱ្យសិស្សចងចាំពីរបៀបបង្កើតប្រយោគសួរជាមួយ What are there on the farm? និង Where does she/he work?

មេរៀនទី២ : សត្វក្នុងកសិដ្ឋាន

Unit 2: Animals On The Farm

រយៈពេល ២ ម៉ោង

១. ឋត្តុបំណង (Objective)

- អានពាក្យ chicken, cow, duck, egg, ox និង pig ជាមួយនឹងគ្រូ
- សរសេរពាក្យ chicken, cow, duck, egg, ox និង pig ដោយបង្ហាញរូបភាពដែលត្រូវ នឹងពាក្យនោះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ ការអានអត្ថបទខ្លីៗ ការសន្ទនា ការនិយាយ និងសំណេរពាក្យបំពេញចន្លោះខ្វះខាត។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ chicken, cow, duck, egg, ox និង pig
- ហ្វឺត ឬដីស និងក្តារខៀន
- ខ្សែអាត់សម្លេង CD ឬ VCD។

៣. ជំនាំបង្រៀន (Teaching Process)

A. រៀនពាក្យ (Vocabulary)

ចូរមើលរូបភាព។ ស្តាប់ និងថាតាម។ Look at the pictures. Listen and repeat.

គ្រូ : - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់នៅលើក្តារខៀន រួចអានឱ្យ សិស្សស្តាប់ បន្ទាប់ឱ្យ សិស្សថាតាម។

- បកប្រែពាក្យជាភាសាខ្មែរ chicken = សត្វមាន់, cow = មេគោ, duck = សត្វទា, egg = ស៊ុត, ox = គោឈ្មោល និង pig = សត្វជ្រូក។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក។ Spell each word in the box with your partner.

គ្រូ : - ឱ្យសិស្សពីរនាក់ម្តងៗដើម្បីប្រកបពាក្យ។

- *ឧទាហរណ៍* ៖ សិស្សម្នាក់ (A) និយាយថា ៖ Please spell the word chicken. ហើយម្នាក់ទៀត (B) ថា chicken I spell c-h-i-c-k-e-n។

C. អំណាន (Reading)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានអត្ថបទឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សអានតាម

- ពន្យល់ពាក្យពិបាកៗ ឬពាក្យថ្មី
- ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ។

២. ចូរសួរ និងឆ្លើយសំណួរ។ Ask and answer the questions.

គ្រូ :- ឱ្យសិស្សអានអត្ថបទស្ងាត់ៗរៀងៗខ្លួន បន្ទាប់មកចាប់ដៃគូសួរ និងឆ្លើយសំណួរ។

- *ឧទាហរណ៍ៈ* What does Mr. Sot plant?He plants rice.
- ចម្លើយៈ 1. He raises animals on his farm.
  2. He raises ducks, chickens, oxen, pigs and cows.
  3. He sells his farm produce to the market.
  4. His family is very happy.

D. ការសន្ទនា (Conversation)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានសន្ទនាឱ្យសិស្សស្តាប់

- ឱ្យសិស្សពីរនាក់ម្តងៗសន្ទនាគ្នា។
- *ឧទាហរណ៍ៈ* A: Is this Mr. Mao's farm?
  B: Yes, it is.

២. ចូរអនុវត្តជាមួយដៃគូរបស់អ្នក។ Practice with your partner.

គ្រូ : - ឱ្យសិស្សសន្ទនាជាមួយដៃគូដោយប្រើពាក្យឱ្យបានត្រឹមត្រូវ។

- *ឧទាហរណ៍ៈ* A: What animals does Mr. Mao have on the farm?
- ចម្លើយៈ B. pigs, chicken; A. does; B. plants។

E. សំណេរ (Writing)

ចូរសរសេរពាក្យដែលខ្វះនៅក្នុងសៀវភៅសរសេររបស់អ្នក។ Write the missing words in your notebook.

គ្រូ : - ឱ្យសិស្សសរសេរពាក្យក្នុងប្រអប់បំពេញនៅចន្លោះខ្វះខាត។

- *ឧទាហរណ៍* ៖ (1) plants.
- ចម្លើយ ៖ (2)animals; (3)chickens; (4)pigs; (5) cows; (6). market។

គួរចងចាំ (Remember)

គ្រូ : - បញ្ជាក់ប្រាប់សិស្សឱ្យចងចាំពាក្យ chicken, cow, duck, egg, ox និង pig។

- ប្រាប់ឱ្យសិស្សចងចាំពីពាក្យដែលមានព្យញ្ជនៈផ្សំ ch នៅពីមុខពាក្យ (chicken)។
- ប្រាប់ឱ្យសិស្សចងចាំពីរបៀបបង្កើតប្រយោគសួរជាមួយ What does Mr. Sot plant? Where doese he raise the animals? និង How does his family feel?

មេរៀនទី៣ : របរកសិកម្ម

Unit 3: Farming

រយៈពេល ២ ម៉ោង

១. វត្ថុបំណង (Objective)

- អានពាក្យ cut, dig, field, plant និង plough ជាមួយនឹងគ្រូ
- សរសេរពាក្យ cut, dig, field, plant និង plough ដោយបង្ហាញរូបភាពដែលត្រូវនឹងពាក្យនោះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ ការអានអត្ថបទខ្លីៗ ការសន្ទនា ការនិយាយ និងសំណេរពាក្យបំពេញចន្លោះខ្វះខាត។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ cut, dig, field, plant និង plough
- ហ្វឺត ឬដីស និងក្តារខៀន
- ខ្សែអាត់សម្លេង CD ឬ VCD។

៣. ជំនាំបង្រៀន (Teaching Process)

A. រៀនពាក្យ (Vocabulary)

ចូរមើលរូបភាព។ ស្តាប់ និងថាតាម។ Look at the pictures. Listen and repeat.

គ្រូ : - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់នៅលើក្តារខៀន រួចអានឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សថាតាម។

- បកប្រែពាក្យជាភាសាខ្មែរ cut = កាត់, dig = ជីក, field = ទីវាល, plant = ដាំ និង plough = ភ្ជួរដី។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក។ Spell each word in the box with your partner.

គ្រូ : - ឱ្យសិស្សពីរនាក់ម្តងៗដើម្បីប្រកបពាក្យ។

- *ឧទាហរណ៍៖* សិស្សម្នាក់ (A) និយាយថា Please spell the word cut. ហើយម្នាក់ទៀត (B) ថា cut I spell c-u-t។

C. អំណាន (Reading)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានអត្ថបទឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សអានតាម

- ពន្យល់ពាក្យពិបាកៗ ឬពាក្យថ្មី
- ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ។

២. ចូរសួរ និងឆ្លើយសំណួរ។ Ask and answer the questions.

គ្រូ : - ឱ្យសិស្សអានអត្ថបទស្ងាត់ៗរៀងៗខ្លួន បន្ទាប់មកចាប់ដៃគូសួរ និងឆ្លើយសំណួរ។

- *ឧទាហរណ៍៖* Who ploughs the rice field? The Cambodian farmers.
- ចម្លើយ៖
  1. They plough their rice field at the early rainy season.
  2. They dig the soil to make levee.
  3. They cut the edge of the seedings and plant.
  4. The rice is green.

D. ការសន្ទនា (Conversation)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានសន្ទនាឱ្យសិស្សស្តាប់

- ឱ្យសិស្សពីរនាក់ម្តងៗសន្ទនាគ្នា។
- *ឧទាហរណ៍ ៖* A: What are your parents?
  B: They are farmers.

២. ចូរអនុវត្តជាមួយដៃគូរបស់អ្នក។ Practice with your partner.

គ្រូ : - ឱ្យសិស្សសន្ទនាជាមួយដៃគូដោយប្រើពាក្យឱ្យបានត្រឹមត្រូវ។

- *ឧទាហរណ៍៖* A: Hello, Makara. What are your parents?
- ចម្លើយ៖ B. are; A. do; B. field; A. ploughs; B. plant.។

E. សំណេរ (Writing)

ចូរសរសេរពាក្យដែលខ្វះនៅក្នុងសៀវភៅសរសេររបស់អ្នក។ Write the missing words in your notebook.

- *ឧទាហរណ៍៖* (1) plough.
- ចម្លើយ៖ (2) field; (3) dig; (4) cut; (5) plant។

គួរចងចាំ (Remember)

គ្រូ : - បញ្ជាក់ប្រាប់សិស្សឱ្យចងចាំពាក្យ cut, dig, field, plant និង plough។

- ប្រាប់ឱ្យសិស្សចងចាំរបៀបបង្កើតទម្រង់សួរជាមួយ What do you dig the soil? What do they do after pulling out seeding? When do the farmers plough thier rice field? និង Who ploughs the rice field?។

មេរៀនទី៤ : នៅផ្សារ

Unit 4: At A Market

រយៈពេល ២ ម៉ោង

១. គោលបំណង (Objective)

- អានពាក្យ cloth, food, bag, thick និង thin ជាមួយនឹងគ្រូ
- សរសេរពាក្យ cloth, food, bag, thick និង thin ដោយបង្ហាញរូបភាពដែលត្រូវនឹងពាក្យនោះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ ការអានអត្ថបទខ្លីៗ ការសន្ទនា ការនិយាយ និងសំណេរពាក្យបំពេញចន្លោះខ្វះខាត។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យត្រូវនឹងពាក្យ cloth, food, bag, thick និង thin
- ហ្វឺត ឬដីស និងក្តារខៀន
- ខ្សែអាត់សម្លេង CD ឬ VCD។

៣. ជំនាំបង្រៀន (Teaching Process)

A. រៀនពាក្យ (Vocabulary)

ចូរមើលរូបភាព។ ស្តាប់ និងថាតាម។ Look at the pictures. Listen and repeat.

គ្រូ : - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់នៅលើក្តារខៀន រួចអានឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សថាតាម។

- បកប្រែពាក្យជាភាសាខ្មែរ cloth = ក្រណាត់, food = អាហារ, bag = កាតាប, thick = ក្រាស់ និង thin = ស្តើង។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក។ Spell each word in the box with your partner.

គ្រូ : - ឱ្យសិស្សពីរនាក់ម្តងៗដើម្បីប្រកបពាក្យ។

- *ឧទាហរណ៍៖* សិស្សម្នាក់ (A) និយាយថា Please spell the word food. ហើយម្នាក់ទៀត (B) ថា food I spell f-o-o-d។

C. អំណាន (Reading)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានឱ្យសិស្សស្តាប់ បន្ទាប់ឱ្យសិស្សថាតាម

- ពន្យល់ពាក្យពិបាកៗ ឬពាក្យថ្មី
- ឱ្យសិស្សម្នាក់អានអត្ថបទ និង ម្នាក់ទៀតបកប្រែជាភាសាខ្មែរ។

២. ចូរសួរ និងឆ្លើយសំណួរ។ Ask and answer the questions.

គ្រូ : - ឱ្យសិស្សអានអត្ថបទស្ងាត់ៗរៀងៗខ្លួន បន្ទាប់ចាប់ដៃគូសួរ នឹងឆ្លើយសំណួរ។

- *ឧទាហរណ៍ ៖* Where is the market?
  The market is in the village.
- **ចម្លើយ ៖**
  1. His mother buys a bag, thin and thick books.
  2. She sells bags and books.
  3. Ms. Sophy.
  4. Mr. Thea's shop.

D. **ការសន្ទនា** (Conversation)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានសន្ទនាឱ្យសិស្សស្តាប់

- ឱ្យសិស្សពីរនាក់ម្តងៗសន្ទនាគ្នា។
- *ឧទាហរណ៍ ៖* Excuse me. Where is Ms. Sophea's shop? It's next to Ms. Daneth's shop.

២. ចូរអនុវត្តជាមួយដៃគូរបស់អ្នក។ Practice with your partner.

គ្រូ : - ឱ្យសិស្សសន្ទនាជាមួយដៃគូដោយប្រើពាក្យឱ្យបានត្រឹមត្រូវ។

- *ឧទាហរណ៍ ៖* A: Excuse me. Where is Ms. Sophea's shop?
- ចម្លើយ ៖ B. shop, A. does, sell, A. food។

E. **សំណេរ** (Writing)

ចូរសរសេរពាក្យដែលខ្វះនៅក្នុងសៀវភៅសរសេររបស់អ្នក។ Write the missing words in your notebook.

- *ឧទាហរណ៍ ៖* (1) bag.
- ចម្លើយ ៖ (2) thin; (3) thick; (4) clothes; (5) food។

គួរចងចាំ (Remember**)**

គ្រូ : - បញ្ជាក់ប្រាប់សិស្សឱ្យចងចាំពាក្យ cloth, food, bag, thick និង thin។

- ប្រាប់ឱ្យសិស្សចងចាំពីពាក្យដែលមានព្យញ្ជនៈផ្សំ th នៅពីក្រោយពាក្យ (thick, thin) និង th នៅពីក្រោយពាក្យ (cloth)។
- ប្រាប់ឱ្យសិស្សចងចាំពីរបៀបបង្កើតទម្រង់សួរជាមួយ Where is the market? What does Mr. Lina sell? Who sells clothes? និង Where does he buy?

មេរៀនទី៥ : រំលឹកមេរៀនឡើងវិញ

Unit 5: Review

រយៈពេល ២ ម៉ោង

១. ឥតុបំណង (Objective)

- អានពាក្យដែលមាននៅក្នុងប្រអប់ជាមួយនឹងគ្រូ
- បង្ហាញពីរបៀបបង្កើតប្រយោគសួរ និងប្រយោគស្រប ដើម្បីឱ្យសិស្សអនុវត្ត
- បង្ហាញរូបភាព ដើម្បីឱ្យសិស្សមើលរូប ហើយឆ្លើយពាក្យឱ្យត្រូវតាមរូបភាពនីមួយៗ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ និងសំណេរពាក្យបំពេញចន្លោះខ្វះខាត។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ sheep, hand, pond, plough, plant, sand, chicken, cloth, thick, thin, food, field, bag និង farm។
- ហ្វឺត ឬដីស និងក្តារខៀន
- ខ្សែអាត់សម្លេង CD ឬ VCD។

៣. ជំនាំបង្រៀន (Teaching process)

A. វេយ្យាករណ៍ (Language Focus)

គ្រូ : - ឱ្យសិស្សបង្កើតប្រយោគសួរ និងប្រយោគឆ្លើយ រួចអនុវត្តជាមួយដៃគូ ដោយម្នាក់ជាអ្នកសួរ និងម្នាក់ទៀតជាអ្នកឆ្លើយ។

A: What are there on the farm?

B: They are some cows, ducks, chickens, pigs, vegetables and fruit trees.

A: What do they plant on the field?

B: They plant rice on the field.

A: What does she/he raise the ducks?

B: She/He raises them on the farm.

A: How many sheep does she/he raise?

B: She/He raises 10 sheep.

B. ស្តាប់ និងនិយាយ (Listening and Speaking)

១. ចូរស្តាប់ និងនិយាយពាក្យនៅក្នុងប្រអប់។ Listen and say the words in the box.

គ្រូ : - ឱ្យសិស្សដឹងពីសូរសម្លេងនៃព្យញ្ជនៈផ្សំ

- អានពាក្យឱ្យសិស្សស្តាប់ បន្ទាប់ឱ្យមកសិស្សអានតាម។
- *ឧទាហរណ៍៖* sh (sheep …)

២. ចូរមើលរូបភាព។ ឆ្លើយពាក្យឱ្យត្រូវតាមរូបភាពនីមួយៗ។ Look at the pictures. Read the word of each picture.

គ្រូ : - ឱ្យសិស្សលើករូបភាពម្តងមួយៗ រីឯសិស្សដទៃទៀតអាចឆ្លើយពាក្យឱ្យត្រូវទៅតាមរូបនីមួយៗ។

- *ឧទាហរណ៍៖* (អាចចម្លងរូបភាពជាក់) រូបដៃ សិស្សត្រូវឆ្លើយថា hand។
- ចម្លើយ៖ pond, sand, sheep, chicken, cloth, thick និង thin។

C. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនៅក្នុងប្រអប់។ Spell the words in the box.

គ្រូ : - ឱ្យសិស្សពីរនាក់ម្តងៗដើម្បីប្រកបពាក្យ។

- *ឧទាហរណ៍ ៖* សិស្សម្នាក់ (A) និយាយថា Please spell the word plant. ហើយម្នាក់ទៀត (B) ថា plant I spell p-l-a-n-t។

D. សំណេរ (Writing)

ចូរសរសេរពាក្យដែលខ្វះនៅក្នុងសៀវភៅសរសេររបស់អ្នក។ Write the missing words in your notebook.

គ្រូ : - ឱ្យសិស្សសរសេរពាក្យក្នុងប្រអប់បំពេញនៅចន្លោះខ្វះខាត។

- *ឧទាហរណ៍៖* (1) chickens.
- ចម្លើយ៖ (2) pigs; (3) plants; (4) farm; (5) bag; (6) thin; (7) thick។

ជំពូកទី៣

CHAPTER 3

សាលារៀន និងគ្រួសារ

School And Family

មេរៀនទី១ : សមាជិកគ្រួសារ

Unit 1: Family Members

រយៈពេល ២ ម៉ោង

១. ឥតុបំណង (Objective)

- អានពាក្យ brother, daddy, mummy, parents និង sister ជាមួយគ្រូ
- សរសេរពាក្យ brother, daddy, mummy, parents និង sister ដោយបង្ហាញរូបភាពដែលត្រូវនឹងពាក្យនោះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ អំណានអត្ថបទខ្លីៗ ការសន្ទនា ការនិយាយ និងសំណេរ។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ brother, daddy, mummy, parents និង sister
- ហ្វឺត ឬដីស និងក្តារខៀន
- ខ្សែអាត់សម្លេង CD ឬ VCD។

៣. ជំនាំបង្រៀន (Teaching Process)

A. រៀនពាក្យ (Vocabulary)

ចូរមើលរូបភាព។ ស្តាប់ និងថាតាម។ Look at the pictures. Listen and repeat.

គ្រូ : - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់នៅលើក្តារខៀន រួចអានឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សថាតាម។

- បកប្រែពាក្យជាភាសាខ្មែរ daddy = ឪពុក, mummy = ម្តាយ, parents = ឪពុកម្តាយ, sister = បងប្អូនស្រី។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក។ Spell each word in the box with your partner.

គ្រូ : - ឱ្យសិស្សពីរនាក់ម្តងៗដើម្បីប្រកបពាក្យ។

- *ឧទាហរណ៍* ៖ សិស្សម្នាក់(A) និយាយថា Please spell the word parents. ហើយម្នាក់ទៀត (B) ថា parents I spell p-a-r-e-n-t-s។

C. អំណាន (Reading)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានឱ្យសិស្សស្តាប់ បន្ទាប់ឱ្យសិស្សថាតាម
- ពន្យល់ពាក្យពិបាកៗ ឬពាក្យថ្មី
- ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ។

២. ចូរសួរ និងឆ្លើយសំណួរ។ Ask and answer the questions.

គ្រូ : - ឱ្យសិស្សអានអត្ថបទស្ងាត់ៗរៀងៗខ្លួន បន្ទាប់មកចាប់ដៃគូសួរ និងឆ្លើយសំណួរ។
- *ឧទាហរណ៍៖* Who is Sophat? He is Chenda's brother.
- ចម្លើយ៖ 1. She is chenda's sister.
2. He is Chenda's daddy.
3. Her parents are Sok and Linda.
4. She is 6 years old.

D. ការបញ្ចេញសម្លេងជាមួយស្រះផ្សំ

ស្តាប់ ចង្អុល និងថាតាម។ Listen, point and say.

គ្រូ : - អានឱ្យសិស្សស្តាប់ដោយប្រើបណ្ណពាក្យ និងបណ្ណរូបភាព បន្ទាប់មកឱ្យសិស្សអានតាម
- បកប្រែពាក្យ feet = ជើង, tree = ដើមឈើ, queen = ព្រះរាជិនី, green = ពណ៌បៃតង និង teeth = ធ្មេញ។

E. ការសន្ទនា (Conversation)

ចូរស្តាប់តាមគ្រូរបស់អ្នក បន្ទាប់មកសន្ទនាជាមួយដៃគូរបស់អ្នក។ Listen to your teacher and practice with your partner.

គ្រូ : - អានសន្ទនាឱ្យសិស្សស្តាប់
- ឱ្យសិស្សពីរនាក់ម្តងៗសន្ទនាគ្នា។
- *ឧទាហរណ៍៖* A: How are you Chenda?
B: I'm fine, thanks. And you?
- ឱ្យសិស្សសន្ទនាជាមួយដៃគូដោយប្រើឈ្មោះ និងសកម្មភាពផ្ទាល់ខ្លួន តាមគំរូសន្ទនាដែលមានស្រាប់។

F. សំណេរ (Writing)

១. ចូរសរសេរពាក្យឱ្យបានត្រឹមត្រូវនៅក្នុងសៀវភៅសរសេររបស់អ្នក។ Write the missing words in your notebook.

គ្រូ : - សរសេរលំហាត់ពាក្យនៅលើក្តារខៀន បន្ទាប់ឱ្យសិស្សសរសេរពាក្យត្រឹមត្រូវ។
- *ឧទាហរណ៍៖* 1. Teef → feet
- ចម្លើយ៖ 2. ddayd → daddy, 3. teer → tree, 4. issret → sister, 5. neequ → queen
6. robthre → brother។

២. ចូរផ្គូរផ្គងពាក្យខាងលើជាមួយរូបភាពទាំងនេះ ដោយសរសេរក្នុងសៀវភៅរបស់អ្នក។ Match the words above with the pictures and write in your notebook.

- **គ្រូ :** បិតរូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ queen, tree, daddy, brother, sister, feet នៅលើក្តារខៀន បន្ទាប់ឱ្យសិស្សធ្វើការផ្គូរផ្គង ។
- ចម្លើយ៖ a. queen, b. tree, c. daddy, d. brother, e. sister, f. feet ។

គួរចងចាំ (Remember)

គ្រូ : - បញ្ជាក់ប្រាប់សិស្សឱ្យចងចាំពាក្យ brother, daddy, mummy, parents, sister និងការប្រកបពាក្យជាមួយស្រះផ្សំ ee (green, tree, feet, queen, teeth) ។
- ប្រាប់ឱ្យសិស្សចងចាំពីរបៀបបង្កើតប្រយោគសួរជាមួយ Who is Chenda's brother? Who is her mummy? Who are Chenda's parents?

មេរៀនទី២ : ទៅសាលារៀន

Unit 2: Going To School

រយៈពេល ២ ម៉ោង

១. គោលបំណង (Objective)

- អានពាក្យ ride, walk, school, house, bicycle និង classmate ជាមួយនឹងគ្រូ
- សរសេរពាក្យ ride, walk, school, house, bicycle និង classmate ដោយបង្ហាញរូបភាពដែលត្រូវនឹងពាក្យនោះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ អំណានអត្ថបទខ្លីៗ ការសន្ទនា ការនិយាយ និងសំណេរ។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ ride, walk, school, house, bicycle និង classmate
- ហ្វឺត ឬដីស និងក្តារខៀន
- ខ្សែអាត់សម្លេង CD ឬ VCD។

៣. ដំណាំបង្រៀន (Teaching Process)

A. រៀនពាក្យ (Vocabulary)

ចូរមើលរូបភាព។ ស្តាប់ និងថាតាម។ Look at the pictures. Listen and repeat.

គ្រូ : - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់នៅលើក្តារខៀន រួចអានឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សថាតាម។

- បកប្រែពាក្យជាភាសាខ្មែរ ride = ជិះ, walk = ដើរ, school= សាលារៀន, house = ផ្ទះ, bicycle = កង់, classmate = មិត្តរួមថ្នាក់។

B. ការប្រកបពាក្យ (Spelling)

- ខ្សែអាត់សម្លេង CD ឬ VCD។

៣. ជំនាំបង្រៀន (Teaching process)

A. វេយ្យាករណ៍ (Language Focus)

គ្រូ : - ឱ្យសិស្សបង្កើតសំណួរ និងចម្លើយ បន្ទាប់ឱ្យសិស្សអនុវត្តជាមួយដៃគូ ដោយម្នាក់ជាអ្នកសួរ និងម្នាក់ទៀតជាអ្នកឆ្លើយ។ *ឧទាហរណ៍ ៖*

What do you want to buy?
I want to buy vegetables.

B. ស្តាប់ និងនិយាយ (Listening and Speaking)

១. ចូរស្តាប់ និងនិយាយពាក្យក្នុងប្រអប់។ Listen and say the words in the box.

គ្រូ : - អានពាក្យក្នុងប្រអប់ម្តងមួយពាក្យៗឱ្យសិស្សស្តាប់ បន្ទាប់ឱ្យសិស្សថាតាម។

- *ឧទាហរណ៍ ៖* គ្រូអានពាក្យ apple រួចសិស្សក្នុងថ្នាក់អានតាម apple។

2. ចូរមើលរូបភាព។ ចូរឆ្លើយពាក្យឱ្យត្រូវតាមរូបភាពនីមួយៗ។ Look at the pictures. Read the word of each picture.

គ្រូ : - ឱ្យសិស្សលើករូបភាពម្តងមួយៗ រីឯសិស្សដទៃអាចឆ្លើយពាក្យឱ្យត្រូវទៅតាមរូបនីមួយៗ។

- *ឧទាហរណ៍ ៖* រូបផ្លែដូង សិស្សត្រូវឆ្លើយថា coconut។
- ចម្លើយ ៖ (អាចចម្លងរូបភាពជាក់) guava, durian, banana, tomato, papaya, eggplant, meat, football, beef និង bag។

C. ការនិយាយ (Speaking)

ចូរប្រើពាក្យនៅក្នុងប្រអប់។ សួរ និងឆ្លើយសំណួរជាមួយដៃគូរបស់អ្នក។ Look at the pictures. Ask and answer the questions with your partner.

គ្រូ : - ឱ្យសិស្សសន្ទនាជាមួយដៃគូដោយប្រើពាក្យឱ្យបានត្រឹមត្រូវ។

- ចម្លើយ ៖ A. buy; B. rackets; B. them; B. 5,000; B. school ។

D. **សំណេរ** (Writing)

ចូរសរសេរចំនួនលេខជាពាក្យនៅក្នុងសៀវភៅសរសេររបស់អ្នក ។ Write the word of each picture in your notebook.

គ្រូ : - សរសេរចំនួនលេខលើក្តារខៀន បន្ទាប់មកឱ្យសិស្សបំពេញជាពាក្យ (អក្សរ) ។

- *ឧទាហរណ៍ ៖* 11 : eleven.

ជំពូកទី៥
CHAPTER 5
ការបំផ្លែងសូរ 'e'
Magic 'e'

មេរៀនទី១: ការបំផ្លែងសូរ 'e' សម្លេង 'a'
Unit 1: Magic 'e' Sound 'a'

រយៈពេល ២ ម៉ោង

១. ឥស្តុបំណង (Objective)

- អានពាក្យដែលមានសម្លេង a ជាមួយនឹងគ្រូ
- សរសេរពាក្យ cake, face, game, gate, lake និង tape ដោយបង្ហាញរូបភាពដែលត្រូវនឹងពាក្យនោះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ ការសន្ទនា អំណានអត្ថបទខ្លីៗ ការនិយាយ និងសំណេរប្រយោគខ្លីៗ។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ cake, face, game, gate, lake និង tape
- ហ្វឺត ឬដីស និងក្តារខៀន
- ខ្សែអាត់សម្លេង CD ឬ VCD។

៣. ជំនាំបង្រៀន (Teaching process)

A. រៀនពាក្យ (Vocabulary)

ការបំផ្លែងសូរ ‘e’ ធ្វើឱ្យអក្សរ ‘a’ ប្រែប្រួលសម្លេងរបស់វា។ Magic ‘e’ makes the letter ‘a’ sound its name. *ឧទាហរណ៍*៖ tap → tape។

ចូរមើលរូបភាព។ ស្តាប់ និងថាតាម។ Look at the pictures. Listen and repeat.

គ្រូ: - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់នៅលើក្តារខៀន រួចអានឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សថាតាម។

- បកប្រែពាក្យជាភាសាខ្មែរ cake = នំ, face = មុខ, game = ល្បែង, lake = បឹង, gate = ក្លោងទ្វារ, tape = ខ្សែអាត់។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក។ Spell each word in the box with your partner.

គ្រូ: - ឱ្យសិស្សពីរនាក់ម្តងៗដើម្បីប្រកបពាក្យ។

- *ឧទាហរណ៍* ៖ សិស្សម្នាក់ (A) និយាយថា Please spell the word cake. ហើយម្នាក់ទៀត (B) ថា cake I spell c-a-k-e ។

C. ការសន្ទនា (Conversation)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក ។ Listen to your teacher and repeat.

គ្រូ : - អានសន្ទនាឱ្យសិស្សស្តាប់

- ឱ្យសិស្សម្តងពីរនាក់ៗសន្ទនាគ្នា ។ *ឧទាហរណ៍*៖

Bol: Hi Raksa! Why are you standing near the gate?

Raksa: Hi Bol! I am waiting for my father.

២. ចូរស្តាប់ឡើងវិញ បន្ទាប់សន្ទនាជាមួយដៃគូរបស់អ្នក ។ Listen again and practice with your partner.

គ្រូ : - ឱ្យសិស្សសន្ទនាជាមួយដៃគូដោយប្រើឈ្មោះ និងសកម្មភាពផ្ទាល់ខ្លួន ។ *ឧទាហរណ៍* ៖

Hi _____! Why are you standing near the gate?
Hi _____! I am waiting for my father.

D. អំណាន (Reading)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក ។ Listen to your teacher and repeat.

គ្រូ : - អានអត្ថបទឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សអានតាម

- ពន្យល់ពាក្យពិបាកៗ ឬពាក្យថ្មី

- ឱ្យសិស្សម្នាក់អានអត្ថបទនិងម្នាក់ទៀតបកប្រែជាភាសាខ្មែរ ។

២. ចូរសួរ និងឆ្លើយសំណួរ ។ Ask and answer the questions.

គ្រូ : - ឱ្យសិស្សអានអត្ថបទស្ងាត់ៗរៀងៗខ្លួនបន្ទាប់ឆ្លើយនឹងសំណួរ ។ *ឧទាហរណ៍*៖

When is Raksa's birthday?
Her birthday is 19 the June.

- ចម្លើយ ៖1) She is ten years old this year.

2) Her birthday is near the lake this year.

3) Yes, they do.

4) After swimming they eat the cakes, play a tape and sing and dance.

E. ការនិយាយ (Speaking)

ចូរមើលរូបភាព បន្ទាប់អនុវត្តជាមួយដៃគូរបស់អ្នក ។ Look at the pictures and practice with your partner.

គ្រូ : - ផ្តល់រូបភាពឱ្យសិស្សដើម្បីបង្ហាញ ដោយសួរមិត្តរួមថ្នាក់ពីអត្ថន័យរបស់រូបភាពទាំងនោះ ។

- *ឧទាហរណ៍*៖ សិស្សម្នាក់បង្ហាញរូបភាព cake ដោយសួរថា

A: What do her parents make for her party? ហើយសិស្សម្នាក់ទៀតឆ្លើយថា

B: They make the cake for her party.

F. សំណេរ (Writing)

ចូរសរសេរឱ្យបានបួនប្រយោគ ដោយប្រើពាក្យដែលមានសម្លេង 'a' នៅក្នុងសៀវភៅសរសេររបស់អ្នក ។
Write four sentences by using the words from sound 'a' in your notebook.

គ្រូ : - ឱ្យសិស្សប្រើពាក្យ lake, cake, face, game, gate និង tape ដើម្បីតាក់តែងប្រយោគ។

- *ឧទាហរណ៍* ៖ She swims with her friends in the lake.

គួរចងចាំ (Remember**)**

គ្រូ : - បញ្ជាក់ប្រាប់សិស្សអំពីពាក្យដែលមានសម្លេង ‘a’ ។

- *ឧទាហរណ៍*៖ tap → tape ។
- ឱ្យសិស្សចងចាំពាក្យ : cake, face, game, gate, lake និង tape ។

មេរៀនទី២ : ការបំផ្លែងសូរ 'e' សម្លេង 'i'

Unit 2: Magic 'e' Sound 'i'

រយៈពេល ២ ម៉ោង

១. ឥស្តុបំណង (Objective)

- អានពាក្យដែលមានសម្លេង 'i' ជាមួយនឹងគ្រូ
- សរសេរពាក្យ bike, five, kite, nine, time និង white ដោយបង្ហាញរូបភាពដែលត្រូវនឹងពាក្យនោះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ ការសន្ទនា អំណានអត្ថបទខ្លីៗ ការនិយាយ និងសំណេរប្រយោគខ្លីៗ។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ bike, five, kite, nine, time និង white
- ហ្វឺត ឬដីស និងក្តារខៀន
- ខ្សែអាត់សម្លេង CD ឬ VCD។

៣. ជំនាំបង្រៀន (Teaching process)

A. រៀនពាក្យ (Vocabulary)

- ការបំផ្លែងសូរ 'e' ធ្វើឱ្យអក្សរ 'i' ប្រែប្រួលសម្លេងរបស់វា។ Magic 'e' makes the letter 'i' sound its name. *ឧទាហរណ៍* ៖ kit → kite។
- ចូរមើលរូបភាព។ ស្តាប់ និងថាតាម។ Look at the pictures. Listen and repeat.

គ្រូ : - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់នៅលើក្តារខៀន រួចអានឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សថាតាម។

- បកប្រែពាក្យជាភាសាខ្មែរ bike = កង់, five = ប្រាំ, kite = ខ្លែង, nine = ប្រាំបួន, time = ម៉ោង, white = ពណ៌ស។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក។ Spell each word in the box with your partner.

គ្រូ : - ឱ្យសិស្សម្តងពីរនាក់ៗដើម្បីប្រកបពាក្យ។

- *ឧទាហរណ៍* ៖ សិស្សម្នាក់ (A) និយាយថា Please spell the word bike. ហើយម្នាក់ទៀត (B) ថា bike I spell b-i-k-e។

C. ការសន្ទនា (Conversation)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានសន្ទនាឱ្យសិស្សស្តាប់

- ឱ្យសិស្សពីរនាក់ម្តងៗសន្ទនាគ្នា។ *ឧទាហរណ៍* ៖ Nang: Hello, Mary. How old are you?
  Mary: Hello, Nang. I am nine years old.

២. ចូរស្តាប់ឡើងវិញ បន្ទាប់សន្ទនាជាមួយដៃគូរបស់អ្នក។ Listen again and practice with your partner.

គ្រូ : - ឱ្យសិស្សសន្ទនាជាមួយដៃគូដោយប្រើឈ្មោះ និងសកម្មភាពផ្ទាល់ខ្លួន។ *ឧទាហរណ៍*៖
Hello, _____. How old are you?
Hello, _____. I am ____years old.

D. អំណាន (Reading)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានឱ្យសិស្សស្តាប់ បន្ទាប់ឱ្យសិស្សថាតាម
- ពន្យល់ពាក្យពិបាកៗ ឬពាក្យថ្មី
- ឱ្យសិស្សម្នាក់អានអត្ថបទនិងម្នាក់ទៀតបកប្រែជាភាសាខ្មែរ។

២. ចូរសួរ និងឆ្លើយសំណួរ។ Ask and answer the questions.

គ្រូ : - ឱ្យសិស្សអានអត្ថបទស្ងាត់ៗរៀងៗខ្លួន បន្ទាប់ឆ្លើយនឹងសំណួរ។ *ឧទាហរណ៍* ៖
How old is Mary?
She is ten years old.
- ចម្លើយ ៖ 1) She is in Grade 5.
2) She likes riding her bike to school.
3) It starts at 7 o'clock and ends at 11 o'clock in the morning.
4) It is white.

E. ការនិយាយ (Speaking)

ចូរមើលរូបភាព បន្ទាប់អនុវត្តជាមួយដៃគូរបស់អ្នក។ Look at the pictures and practice with your partner.

គ្រូ : - ផ្តល់រូបភាពឱ្យសិស្សដើម្បីបង្ហាញ ដោយ សួរមិត្តរួមថ្នាក់ពី អត្ថន័យរបស់រូបភាពទាំងនោះ។
- *ឧទាហរណ៍* ៖ សិស្សម្នាក់បង្ហាញរូបភាព bike ដោយសួរថា A: How do you go to school? ហើយសិស្សម្នាក់ទៀតឆ្លើយថា B: I go to school by bike.

F. សំណេរ (Writing)

ចូរសរសេរឱ្យបានបួនប្រយោគ ដោយប្រើពាក្យដែលមានសម្លេង 'i' ចូលក្នុងសៀវភៅរបស់អ្នក។ Write four sentences by using the words from sound 'i' in your notebook.

គ្រូ : - ឱ្យសិស្សប្រើពាក្យ bike, five, kite, nine, time និង white ដើម្បីតាក់តែងប្រយោគ។
- *ឧទាហរណ៍* ៖ She rides her bike to school every day.

គួរចងចាំ (Remember**)**

គ្រូ : - បញ្ជាក់ប្រាប់សិស្សអំពីពាក្យដែលមានសម្លេង 'i'។
- *ឧទាហរណ៍* ៖ kit → kite។
- ឱ្យសិស្សចងចាំពាក្យ : bike, five, kite, nine, time និង white។

មេរៀនទី៣ : ការបំផ្លែងសូរ 'e' សម្លេង 'o'

Unit 3: Magic 'e' Sound 'o'

រយៈពេល ២ ម៉ោង

១. ឋត្តុបំណង (Objective)

- អានពាក្យដែលមានសម្លេង 'o' ជាមួយនឹងគ្រូ
- សរសេរពាក្យ bone, hole, home, rope, rose និង stone ដោយបង្ហាញរូបភាពដែលត្រូវនឹងពាក្យទាំងនោះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ ការសន្ទនា អំណានអត្ថបទខ្លីៗ ការនិយាយ និងសំណេរប្រយោគខ្លីៗ។

៣. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ bone, hole, home, rope, rose និង stone
- ហ្វឺត ឬដីស និងក្តារខៀន
- ខ្សែអាត់សម្លេង CD ឬ VCD។

៣. លំនាំបង្រៀន (Teaching process)

A. រៀនពាក្យ (Vocabulary)

- ការបំផ្លែងសូរ 'e' ធ្វើឱ្យអក្សរ 'o' ប្រែប្រួលសម្លេងរបស់វា។ Magic 'e' makes the letter 'o' sound its name. *ឧទាហរណ៍* ៖ not → note ។
- ចូរមើលរូបភាព។ ស្តាប់ និងថាតាម។ Look at the pictures. Listen and repeat.

គ្រូ : - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់នៅលើក្តារខៀន រួចអានឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សថាតាម។

- បកប្រែពាក្យជាភាសាខ្មែរ bone = ឆ្អឹង, hole = រណ្តៅ, home = ផ្ទះ, rope = ខ្សែ, rose = ផ្កាកុលាប, stone = ថ្ម។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក។ Spell each word in the box with your partner.

គ្រូ : - ឱ្យសិស្សពីរនាក់ម្តងៗដើម្បីប្រកបពាក្យ។

- *ឧទាហរណ៍* ៖ សិស្សម្នាក់ (A) និយាយថា Please spell the word bone. ហើយម្នាក់ទៀត (B) ថា bone I spell b-o-n-e ។

C. ការសន្ទនា (Conversation)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានសន្ទនាឱ្យសិស្សស្តាប់

- ឱ្យសិស្សពីរនាក់ម្តងៗសន្ទនាគ្នា។

ឧទាហរណ៍ ៖ Bol: Hello, Raksaa. What are you doing?
Raksa: Hello, Bol. I am looking for my dog.

២. ចូរស្តាប់ឡើងវិញ បន្ទាប់សន្ទនាជាមួយដៃគូរបស់អ្នក ។ Listen again and practice with your partner.

គ្រូ : - ឱ្យសិស្សសន្ទនាជាមួយដៃគូដោយប្រើឈ្មោះ និងសកម្មភាពផ្ទាល់ខ្លួន ។ *ឧទាហរណ៍ ៖*
Hello, ___. What are you doing?
Hello, ___. I am looking for my dog.

D. អំណាន (Reading)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក ។ Listen to your teacher and repeat.

គ្រូ : - អានឱ្យសិស្សស្តាប់ បន្ទាប់ឱ្យសិស្សថាតាម
- ពន្យល់ពាក្យពិបាកៗ ឬពាក្យថ្មី
- ឱ្យសិស្សម្នាក់អានអត្ថបទនិងម្នាក់ទៀតបកប្រែជាភាសាខ្មែរ ។

២. ចូរសួរ និងឆ្លើយសំណួរ ។ Ask and answer the questions.

គ្រូ : - ឱ្យសិស្សអានអត្ថបទស្ងាត់ៗរៀងៗខ្លួន បន្ទាប់ឆ្លើយនឹងសំណួរ ។ *ឧទាហរណ៍ ៖*
Who are helping their father work?
Bol and his brother are helping him.
- ចម្លើយ ៖ 1) They are helping their father work at their home.
2) They dig the hole to plants the flowers and trees.
3) His father tells him to tie the dog.
4) Because he digs the rose flowers and trees.

E. ការនិយាយ (Speaking)

ចូរមើលរូបភាព បន្ទាប់អនុវត្តជាមួយដៃគូរបស់អ្នក ។ Look at the pictures and practice with your partner.

គ្រូ : - ផ្តល់រូបភាពឱ្យសិស្សដើម្បីបង្ហាញ ដោយសួរមិត្តរួមថ្នាក់ពី អត្ថន័យរបស់រូបភាពទាំងនោះ ។
- *ឧទាហរណ៍ ៖* សិស្សម្នាក់បង្ហាញរូបភាព bone ដោយសួរថា A: What is the dog eating? ហើយសិស្សម្នាក់ទៀតឆ្លើយថា B: The dog is eating the bone.

F. សំណេរ (Writing)

ចូរសរសេរឱ្យបានបួនប្រយោគ ដោយប្រើពាក្យដែលមានសម្លេង ‘o’ ចូលក្នុងសៀវភៅរបស់អ្នក ។ Write four sentences by using the words from sound ‘o’ in your notebook.

គ្រូ : - ឱ្យសិស្សប្រើពាក្យ home, bone, hole, rope, rose និង stone ដើម្បីតាក់តែងប្រយោគ ។
- *ឧទាហរណ៍ ៖* I stay at home on Sunday.

គួរចងចាំ (Remember**)**

គ្រូ : - បញ្ជាក់ប្រាប់សិស្សអំពីពាក្យដែលមានសម្លេង ‘o’ ។ *ឧទាហរណ៍ ៖* not → note ។
- ឱ្យសិស្សចងចាំពាក្យ : bone, hole, home, rope, rose និង stone ។

មេរៀនទី៤ : ការបំផ្លែងសូរ 'e' សម្លេង 'u'

Unit 4: Magic 'e' Sound 'u'

រយៈពេល ២ ម៉ោង

១. ឥស្តុបំណង (Objective)

- អានពាក្យដែលមានសម្លេង 'u' ជាមួយនឹងគ្រូ
- សរសេរពាក្យ cube, flute, June, tube និង use ដោយបង្ហាញរូបភាពដែលត្រូវនឹងពាក្យនោះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ ការសន្ទនា អំណានអត្ថបទខ្លីៗ ការនិយាយ និងសំណេរប្រយោគខ្លីៗ។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ cube, flute, June, tube និង use
- ហ្វឺត ឬដីស និងក្តារខៀន
- ខ្សែអាត់សម្លេង CD ឬ VCD។

៣. ជំនាំបង្រៀន (Teaching process)

A. រៀនពាក្យ (Vocabulary)

- ការបំផ្លែងសូរ 'e' ធ្វើឱ្យអក្សរ 'u' ប្រែប្រួលសម្លេងរបស់វា។ Magic 'e' makes the letter 'u' sound its name. *ឧទាហរណ៍* ៖ us → use ។
- ចូរមើលរូបភាព។ ស្តាប់ និងថាតាម។ Look at the pictures. Listen and repeat.

គ្រូ : - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់នៅលើក្តារខៀន រួចអានឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សថាតាម។

- បកប្រែពាក្យជាភាសាខ្មែរ cube = គូប, flute = ខ្លុយ, June = ខែមិថុនា, tube = បំពង់, use (computer) = ប្រើ (កុំព្យូទ័រ)។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក។ Spell each word in the box with your partner.

គ្រូ : - ឱ្យសិស្សម្តងពីរនាក់ៗដើម្បីប្រកបពាក្យ។

- *ឧទាហរណ៍* ៖ សិស្សម្នាក់ (A) និយាយថា Please spell the word cube. ហើយម្នាក់ទៀត (B) ថា cube I spell c-u-b-e ។

C. ការសន្ទនា (Conversation)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានសន្ទនាឱ្យសិស្សស្តាប់

- ឱ្យសិស្សពីរនាក់ម្តងៗសន្ទនាគ្នា។

ឧទាហរណ៍ ៖ Mary: Hi Nang! When is your birthday?
Nang: Hi Mary! My birthday is in June.

២. ចូរស្តាប់ឡើងវិញ បន្ទាប់សន្ទនាជាមួយដៃគូរបស់អ្នក ។ Listen again and practice with your partner.

គ្រូ : - ឱ្យសិស្សសន្ទនាជាមួយដៃគូដោយប្រើឈ្មោះ និងសកម្មភាពផ្ទាល់ខ្លួន ។ *ឧទាហរណ៍ ៖*

Hi _____! When is your birthday?

Hi _____! My birthday is in _____.

D. អំណាន (Reading)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក ។ Listen to your teacher and repeat.

គ្រូ : - អានឱ្យសិស្សស្តាប់ បន្ទាប់ឱ្យសិស្សថាតាម
- ពន្យល់ពាក្យពិបាកៗ ឬពាក្យថ្មី
- ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ ។

២. ចូរសួរ និងឆ្លើយសំណួរ ។ Ask and answer the questions.

គ្រូ : - ឱ្យសិស្សអានអត្ថបទស្ងាត់ៗរៀងៗខ្លួន បន្ទាប់ឆ្លើយនឹងសំណួរ ។ *ឧទាហរណ៍ ៖*
Who is a painter?
Mary's father is a painter.

- ចម្លើយ ៖ 1) Yes, he does.
2) Yes, she can.
3) She draws the squares, circles, cube, flute and tube.
4) She draws them for her classroom.

E. ការនិយាយ (Speaking)

ចូរមើលរូបភាព បន្ទាប់អនុវត្តជាមួយដៃគូរបស់អ្នក ។ Look at the pictures and practice with your partner.

គ្រូ : - ផ្តល់រូបភាពឱ្យសិស្សដើម្បីបង្ហាញ ដោយសួរមិត្តរួមថ្នាក់ពីអត្ថន័យរបស់រូបភាពទាំងនោះ ។ *ឧទាហរណ៍ ៖* សិស្សម្នាក់បង្ហាញរូបភាព use (computer) ដោយសួរថា A: What does she do? ហើយសិស្សម្នាក់ទៀតឆ្លើយថា B: She uses computer.

F. សំណេរ (Writing)

ចូរសរសេរឱ្យបានបួនប្រយោគ ដោយប្រើពាក្យដែលមានសម្លេង 'u' ចូលក្នុងសៀវភៅរបស់អ្នក ។ Write four sentences by using the words from sound 'u' in your notebook.

គ្រូ : - ឱ្យសិស្សប្រើពាក្យ use, cube, flute, June និង tube ដើម្បីតាក់តែង ប្រយោគ ។
- *ឧទាហរណ៍ ៖* She uses computer to draw the pictures.

គួរចងចាំ (Remember**)**

គ្រូ : - បញ្ជាក់ប្រាប់សិស្សអំពីពាក្យដែលមានសម្លេង 'u' ។
- *ឧទាហរណ៍ ៖* us → use ។
- បញ្ជាក់ប្រាប់សិស្សឱ្យចងចាំពាក្យ ៖ cube, flute, June, tube និង use ។

មេរៀនទី៥ : រំលឹកមេរៀនឡើងវិញ

Unit 5: Review

រយៈពេល ២ ម៉ោង

១. វត្ថុបំណង (Objective)

- អានពាក្យដែលមានសម្លេង ‘a, i, o, u’ ជាមួយនឹងគ្រូ
- បង្ហាញរូបភាពនៃពាក្យ game, face, June, use (computer), nine និង rose ដើម្បីឱ្យសិស្សអាននូវពាក្យទាំងនោះ
- សរសេរពាក្យ lake, nine, bike, bone, flute, use, cake និង hole នៅចន្លោះទំនេរ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ និងសំណេរពាក្យ។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ game, face, June, use (computer), nine និង rose
- ហ្វឺត ឬដីស និងក្តារខៀន
- ខ្សែអាត់សម្លេង CD ឬ VCD។

៣. ជំនាំបង្រៀន (Teaching process)

A. ចូរស្តាប់ និងថាតាម (Listen and repeat)

ការបំផ្លែងសូរ ‘e’ ធ្វើឱ្យសម្លេងស្រៈប្រែប្រួលតាមសម្លេងរបស់វា។ Magic ‘e’ makes the vowel sound its own name.

១. ចូរអនុវត្តពាក្យនៅក្នុងប្រអប់។ Practice the words in the box.

គ្រូ : - អានអត្ថបទឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សថាតាម។

- ឱ្យសិស្សបកប្រែពាក្យក្នុងតារាងជាភាសាខ្មែរ។

២. ចូរមើលរូបភាព បន្ទាប់អានពាក្យឱ្យបានត្រឹមត្រូវតាមសូរសម្លេង។ Look at the pictures and read the words with the correct sound.

គ្រូ : ឱ្យសិស្សម្នាក់លើករូបភាព និងម្នាក់ទៀតអានពាក្យឱ្យបានត្រឹមត្រូវ។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក។ Spell each word in the box with your partner.

គ្រូ : - ឱ្យសិស្សពីរនាក់ម្តងៗដើម្បីប្រកបពាក្យ។ *ឧទាហរណ៍* ៖ សិស្សម្នាក់ (A) និយាយថា Please spell the word hole. ហើយម្នាក់ទៀត (B) ថា hole I spell h-o-l-e។

C. សំណេរ (Writing)

ចូរបំពេញប្រយោគ ដោយប្រើពាក្យនៃការបំផ្លែងសូរ ‘e’ ដូចមានក្នុងប្រអប់។ ចូរសរសេរប្រយោគនៅក្នុងសៀវភៅសរសេររបស់អ្នក។ Complete the sentences with the magic ‘e’ words in the box. Write the sentences in your notebook.

គ្រូ : - ឱ្យសិស្សចម្លងប្រយោគចូលក្នុងសៀវភៅសរសេរ រួចឱ្យបំពេញចន្លោះទំនេរដោយប្រើពាក្យក្នុងប្រអប់។

- *ឧទាហរណ៍ ៖* We are going to swim near the lake.
- **ចម្លើយ ៖** 1. bone; 2. use; 3. cake; 4. bike; 5. hole; 6. flute; 7. nine។

ជំពូកទី៦

CHAPTER 6

អាកាសធាតុ

The Weather

មេរៀនទី១: អាកាសធាតុថ្ងៃនេះ

Unit 1: Today's Weather

រយៈពេល ២ ម៉ោង

១. ភារកិច្ច (Objective)

- អានពាក្យ bright, cloudy, sky, sunny និង windy ជាមួយនឹងគ្រូ
- សរសេរពាក្យ bright, cloudy, sky, sunny, windy និង weather ដោយបង្ហាញរូបភាពដែលត្រូវនឹងពាក្យនោះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ ការសន្ទនា ការបំពេញវេយ្យាករណ៍ អំណានអត្ថបទខ្លីៗ ការនិយាយ និងសំណេរប្រយោគខ្លីៗ។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ bright, cloudy, sky, sunny និង windy
- ហ្វឺត ឬដីស និងក្តារខៀន
- ខ្សែអាត់សម្លេង CD ឬ VCD។

៣. ជំនាំបង្រៀន (Teaching process)

A. រៀនពាក្យ (Vocabulary)

ចូរមើលរូបភាព។ ចូរស្តាប់ និងថាតាម។ Look at the pictures. Listen and repeat.

គ្រូ : - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់នៅលើក្តារខៀន រួចអានឱ្យសិស្សស្តាប់ បន្ទាប់ឱ្យសិស្សថាតាម។

- បកប្រែពាក្យជាភាសាខ្មែរ bright = ភ្លឺ, cloudy = ដែលមានពពក, sky = មេឃ, sunny = ពន្លឺព្រះអាទិត្យ , windy = ដែលមានខ្យល់។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក។ Spell each word in the box with your partner.

គ្រូ : - ឱ្យសិស្សពីរនាក់ម្តងៗដើម្បីប្រកបពាក្យ។

- ឧទាហរណ៍ ៖ សិស្សម្នាក់ (A) និយាយថា Please spell the word sky. និងម្នាក់ទៀត (B) ថា sky I spell s-k-y។

C. ការសន្ទនា (Conversation)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានសន្ទនាឱ្យសិស្សស្តាប់

- ឱ្យសិស្សពីរនាក់ម្តងៗសន្ទនាគ្នា។ *ខ*

ទាហរណ៍ ៖

San: Hello Navy! What's the weather like today?

Navy: Hello San! It's cloudy and windy.

២. ចូរស្តាប់ឡើងវិញ បន្ទាប់មកសន្ទនាជាមួយដៃគូរបស់អ្នក។ Listen again and practice with your partner.

គ្រូ : - ឱ្យសិស្សសន្ទនាជាមួយដៃគូដោយប្រើឈ្មោះផ្ទាល់ខ្លួន។

- *ឧទាហរណ៍ ៖*

Hi _____! What's the weather like today?

Hi _____! It's cloudy and windy.

D. វេយ្យាការណ៍ (Language Focus)

ចូរបន្ថែម "ing" លើកិរិយាស័ព្ទដែលមាននៅក្នុងប្រអប់ ដើម្បីបំពេញប្រយោគ។ Add "ing" to the verbs in the box to complete the sentences.

គ្រូ : - ឱ្យសិស្សចម្លងប្រយោគនៅក្នុងសៀវភៅសរសេរ បន្ទាប់មកឱ្យបំពេញចន្លោះទំនេរដោយប្រើពាក្យក្នុងប្រអប់។

- *ឧទាហរណ៍ ៖* Now it is _____ ing. Now it is raining.

- ចម្លើយ ៖ 1. walk, 2. eat, 3. stand, 4. play, 5. blow។

E. អំណាន (Reading)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានអត្ថបទឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សអានតាម

- ពន្យល់ពាក្យពិបាកៗ ឬពាក្យថ្មី

- ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ។

២. ចូរសួរ និងឆ្លើយសំណួរ។ Ask and answer the questions.

គ្រូ : - ឱ្យសិស្សអានអត្ថបទស្ងាត់ៗរៀងៗខ្លួន រួចឆ្លើយនឹងសំណួរ។

- *ឧទាហរណ៍ ៖* Where is Navy walking?

She is walking in the garden.

- ចម្លើយ ៖ 1) She likes the colours of the flowers and the leaves on the trees.

2) She is standing and smelling the flowers.

3) She feels happy.

F. ការនិយាយ (Speaking)

ចូរមើលរូបភាព បន្ទាប់និយាយពីសកម្មភាពដោយបន្ថែម "ing" លើកិរិយាស័ព្ទ។ Look at the pictures and say the activities by adding "ing" to the verbs.

គ្រូ : - ផ្តល់រូបភាពឱ្យសិស្សដើម្បីបង្ហាញ ដោយសួរមិត្តរួមថ្នាក់ពី អត្ថន័យរបស់រូបភាពទាំងនោះ។

- *ឧទាហរណ៍ ៖* សិស្សម្នាក់បង្ហាញរូបភាព cook ដោយសួរថា A: What is she doing? ហើយសិស្សម្នាក់ទៀតឆ្លើយថា B: She is cooking.

- ចម្លើយ ៖ 1). study; 2). teach; 3). play ។

G. សំណេរ (Writing)

ចូរសរសេរឱ្យបានបួនប្រយោគពីសកម្មភាពដែលអ្នកកំពុងមើលឃើញ ឬកំពុងធ្វើនៅក្នុងសៀវភៅសរសេររបស់អ្នក ។ Write four sentences about the activities you are seeing or doing in your notebook.

ឧទាហរណ៍ ៖ My friends and I are walking to school.

គួរចងចាំ (Remember**)**

គ្រូ : - បញ្ជាក់ប្រាប់សិស្សឱ្យចងចាំពាក្យ bright, cloudy, sky, sunny, windy, weather, cook, study, stand, walk, play, eat, blow និង teach ។

- ប្រាប់ឱ្យសិស្សចងចាំពីរបៀបបន្ថែម “ing” ទៅលើកិរិយាស័ព្ទ ដើម្បីបង្កើតទម្រង់សួរ What is she/he doing? What are you/they doing? និងទម្រង់ឆ្លើយ She/He is eating dinner. They/You are walking to school ។

មេរៀនទី២ : រដូវភ្លៀង
Unit 2: The Rainy Season

រយៈពេល ២ ម៉ោង

១. គោលបំណង (Objective)

- អានពាក្យ rain, drizzle, lightning និង rainbow ជាមួយនឹងគ្រូ
- សរសេរពាក្យ rain, drizzle, lightning និង rainbow ដោយបង្ហាញរូបភាពដែលត្រូវនឹងពាក្យនោះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ ការសន្ទនា ការបំពេញវេយ្យាករណ៍ អំណានអត្ថបទខ្លីៗ ការនិយាយ និងសំណេរប្រយោគខ្លីៗ។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ rain, drizzle, lightning និង rainbow
- ហ្វឺត ឬដីស និងក្តារខៀន
- ខ្សែអាត់សម្លេង CD ឬ VCD។

៣. ជំនាំបង្រៀន (Teaching process)

A. រៀនពាក្យ (Vocabulary)

ចូរមើលរូបភាព។ ស្តាប់ និងថាតាម។ Look at the pictures. Listen and repeat.

គ្រូ : - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់នៅលើក្តារខៀន រួចអានឱ្យសិស្សស្តាប់ បន្ទាប់ឱ្យសិស្សថាតាម។
- បកប្រែពាក្យជាភាសាខ្មែរ rain = ភ្លៀង, drizzle = ភ្លៀងរលឹម, lightning = ផ្លេកបន្ទោរ, rainbow = ឥន្ទនូ។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក។ Spell each word in the box with your partner.

គ្រូ : - ឱ្យសិស្សពីរនាក់ម្តងៗដើម្បីប្រកបពាក្យ។
- *ឧទាហរណ៍* ៖ សិស្សម្នាក់ (A) និយាយថា Please spell the word rain. ហើយម្នាក់ទៀត (B) ថា rain I spell r-a-i-n។

C. ការសន្ទនា (Conversation)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានសន្ទនាឱ្យសិស្សស្តាប់
- ឱ្យសិស្សពីរនាក់ម្តងៗសន្ទនាគ្នា។ *ឧទាហរណ៍* ៖ San: Hi, Navy! Where are you going?
Navy: Hi, San! I'm going to the farm.

២. ចូរស្តាប់ឡើងវិញ បន្ទាប់សន្ទនាជាមួយដៃគូរបស់អ្នក។ Listen again and practice with your partner.

គ្រូ : - ឱ្យសិស្សសន្ទនាជាមួយដៃគូដោយប្រើឈ្មោះ និងសកម្មភាពផ្ទាល់ខ្លួន។ *ឧទាហរណ៍* ៖
Hi _____! Where are you going?

Hi _____! I'm going to the farm.

D. វេយ្យាការណ៍ (Language Focus)

ចូរបន្ថែម "ing" លើកិរិយាស័ព្ទដែលមាននៅក្នុងប្រអប់ ដើម្បីបំពេញប្រយោគ។ Add "ing" to the verbs in the box to complete the sentences.

គ្រូ : - ឱ្យសិស្សចងចាំនូវកិរិយាស័ព្ទ travel → travelling និង drizzle → drizzling

- ឱ្យសិស្សចម្លងប្រយោគចូលក្នុងសៀវភៅសរសេរ បន្ទាប់មកឱ្យបំពេញចន្លោះទំនេរដោយប្រើពាក្យក្នុងប្រអប់។ *ឧទាហរណ៍ ៖* Now it is _____ ing. Now it is raining.

- ចម្លើយ : 1. drizzle; 2. plant; 3. travel; 4. work; 5. stay។

E. អំណាន (Reading)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានអត្ថបទឱ្យសិស្សស្តាប់ បន្ទាប់មកឱ្យសិស្សអានតាម

- ពន្យល់ពាក្យពិបាកៗ ឬពាក្យថ្មី

- ឱ្យសិស្សម្នាក់អានអត្ថបទ និងម្នាក់ទៀតបកប្រែជាភាសាខ្មែរ។

២. ចូរសួរ និងឆ្លើយសំណួរ។ Ask and answer the questions.

គ្រូ : - ឱ្យសិស្សអានអត្ថបទស្ងាត់ៗរៀងៗខ្លួន រួចឆ្លើយនឹងសំណួរ។

ឧទាហរណ៍ ៖ Where is Navy going? She is going to school.

- ចម្លើយ ៖ 1) She is wearing the raincoat because the rain is heavy with thunder and lightning.
2) She is wearing her raincoat.
3) She is walking to school.

F. ការនិយាយ (Speaking)

ចូរមើលរូបភាព បន្ទាប់និយាយពីសកម្មភាពដោយបន្ថែម "ing" លើកិរិយាស័ព្ទ។ Look at the pictures and say the activities by adding "ing" to the verbs.

គ្រូ : - ផ្តល់រូបភាពឱ្យសិស្សដើម្បីបង្ហាញ ដោយសួរមិត្តរួមថ្នាក់ពីអត្ថន័យរបស់រូបភាពទាំងនោះ។

- *ឧទាហរណ៍ ៖* សិស្សម្នាក់បង្ហាញរូបភាព swim ដោយសួរថា A: What is the boy doing? ហើយសិស្សម្នាក់ទៀតឆ្លើយថា B: The boy is swimming.

G. សំណេរ (Writing)

ចូរសរសេរឱ្យបានបួនប្រយោគពីសកម្មភាពបងប្អូនស្រីរបស់អ្នក នៅក្នុងសៀវភៅសរសេររបស់អ្នក។ Write four sentences about your sister's activities in your notebook.

ឧទាហរណ៍ ៖ She is listening to the radio.

គួរចងចាំ (Remember)

គ្រូ : - បញ្ជាក់ប្រាប់សិស្សឱ្យចងចាំពាក្យ dizzle, lightnning, rain, rainbow, travel, watch, stay, thunder, work, grow, swim, wash និង plant។

- ប្រាប់ឱ្យសិស្សចងចាំពីរបៀបបន្ថែម "ing" ទៅលើកិរិយាស័ព្ទដើម្បី បង្កើតប្រយោគសួរ Where is she going?What is she wearing?How is he going to school? និងប្រយោគស្រប The weather is drizzling។

មេរៀនទី៣ : រដូវប្រាំង

Unit 3: The Dry Season

រយៈពេល ២ ម៉ោង

១. វត្ថុបំណង (Objective)

- អានពាក្យ blowing, dry, hot និង shining ជាមួយនឹងគ្រូ
- សរសេរពាក្យ blowing, dry, hot និង shining ដោយបង្ហាញរូបភាពដែលត្រូវនឹងពាក្យនោះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ ការសន្ទនា ការបំពេញវេយ្យាករណ៍ អំណានអត្ថបទខ្លីៗ ការនិយាយ និងសំណេរប្រយោគខ្លីៗ។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ blowing, dry, hot និង shining
- ហ្វឺត ឬដីស និងក្តារខៀន
- ខ្សែអាត់សម្លេង CD ឬ VCD។

៣. ជំនាំបង្រៀន (Teaching process)

A. រៀនពាក្យ (Vocabulary)

ចូរមើលរូបភាព។ ស្តាប់ និងថាតាម។ Look at the pictures. Listen and repeat.

គ្រូ : - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់នៅលើក្តារខៀន រួចអានឱ្យសិស្សស្តាប់ បន្ទាប់ឱ្យសិស្សថាតាម។

- បកប្រែពាក្យជាភាសាខ្មែរ blowing = បក់ផាត់, dry = ស្ងួត, hot = ក្តៅ, shining = បញ្ចេញពន្លឺ។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក។ Spell each word in the box with your partner.

គ្រូ : - ឱ្យសិស្សពីរនាក់ម្តងៗដើម្បីប្រកបពាក្យ។

- ឧទាហរណ៍៖ សិស្សម្នាក់ (A) និយាយថា Please spell the word dry. ហើយម្នាក់ទៀត (B) ថា dry I spell d-r-y។

C. ការសន្ទនា (Conversation)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានសន្ទនាឱ្យសិស្សស្តាប់

- ឱ្យសិស្សពីរនាក់ម្តងៗសន្ទនាគ្នា។

ឧទាហរណ៍៖ Dara: Hi Rina! Are you hot today?

Rina: Hi Dara! Yes, I'm hot because the sun is shining today.

២. ចូរស្តាប់ឡើងវិញ បន្ទាប់សន្ទនាជាមួយដៃគូរបស់អ្នក។ Listen again and practice with your partner.

គ្រូ : - ឱ្យសិស្សសន្ទនាជាមួយដៃគូដោយប្រើឈ្មោះ និងសកម្មភាពផ្ទាល់ខ្លួន។ *ឧទាហរណ៍៖*

Hi _____! Are you hot today?

Hi _____! Yes, I'm hot because the sun is shining today.

D. វេយ្យាការណ៍ (Language Focus)

ចូរបន្ថែម “ing” ជាមួយកិរិយាស័ព្ទក្នុងប្រអប់ ដើម្បីបំពេញប្រយោគ។ Add “ing” to the verbs in the box to complete the sentences.

គ្រូ : - ឱ្យសិស្សចងចាំនូវកិរិយាស័ព្ទ leave → leaving, shine → shining និង sit → sitting។

- ឱ្យសិស្សចម្លងប្រយោគចូលក្នុងសៀវភៅសរសេរ បន្ទាប់ឱ្យបំពេញចន្លោះទំនេរដោយប្រើពាក្យក្នុងប្រអប់។ *ឧទាហរណ៍*៖ Dara is _____ ing. Dara is enjoying sport.
- ចម្លើយ ៖ 1. shine, 2. run, 3. visit, 4. sit, 5. leave។

E. អំណាន (Reading)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានឱ្យសិស្សស្តាប់ បន្ទាប់ឱ្យសិស្សថាតាម

- ពន្យល់ពាក្យពិបាកៗ ឬពាក្យថ្មី
- ឱ្យសិស្សម្នាក់អានអត្ថបទនិងម្នាក់ទៀតបកប្រែជាភាសាខ្មែរ។

២. ចូរសួរ និងឆ្លើយសំណួរ។ Ask and answer the questions.

គ្រូ : - ឱ្យសិស្សអានអត្ថបទស្ងាត់ៗរៀងៗខ្លួន បន្ទាប់ឆ្លើយនឹងសំណួរ។ *ឧទាហរណ៍* ៖
What does Dara play? He plays football.

- ចម្លើយ ៖ 1) He spends one hour.
  2) He likes playing in the dry season.
  3) Because sport makes them healthy.
  4) They feel happy.

F. ការនិយាយ (Speaking)

ចូរមើលរូបភាព បន្ទាប់មករៀបរាប់ពីសកម្មភាព ដោយបន្ថែម “ing” លើកិរិយាស័ព្ទ។ Look at the pictures and say the activities by adding “ing” to the verbs.

គ្រូ : - ផ្តល់រូបភាពឱ្យសិស្សដើម្បីបង្ហាញ ដោយសួរមិត្តរួមថ្នាក់ពី អត្ថន័យរបស់រូបភាពទាំងនោះ។

- *ឧទាហរណ៍* ៖ សិស្សម្នាក់បង្ហាញរូបភាព football ដោយសួរថា A: What are they doing? ហើយសិស្សម្នាក់ទៀតឆ្លើយថា B: They are playing football.
- ចម្លើយ ៖ 1). plant; 2). watch; 3). wash។

G. សំណេរ (Writing)

- ចូរសរសេរឱ្យបានបួនប្រយោគអំពីអាកាសធាតុ នៅក្នុងសៀវភៅសរសេររបស់អ្នក។ Write four sentences about the weather in your notebook. *ឧទាហរណ៍* ៖ It is raining today.
- ចម្លើយ ៖ 1). visit; 2). feel; 3). sit។

គួរចងចាំ (Remember**)**

គ្រូ : - បញ្ជាក់ប្រាប់សិស្សឱ្យចងចាំពាក្យ blowing, dry, hot, shining, sit, feel, shine, enjoy, visit, leave, run និង play។

- បញ្ជាក់ប្រាប់សិស្សឱ្យចងចាំពីរបៀបបន្ថែម “ing” ជាមួយកិរិយាស័ព្ទដើម្បីបង្កើតជាប្រយោគសួរ Are they running againt each other? និងប្រយោគស្រប I am sitting next to her. She is visiting the doctor. We are leaving the house.

មេរៀនទី៤ : ទឹកជំនន់

Unit 4: The Flood

រយៈពេល ២ ម៉ោង

១. វត្ថុបំណង (Objective)

- អានពាក្យ flood, North, East, South និង West ជាមួយនឹងគ្រូ
- សរសេរពាក្យ flood, North, East, South និង West ដោយបង្ហាញរូបភាពដែលត្រូវនឹងពាក្យនោះ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ ការសន្ទនា ការបំពេញវេយ្យាករណ៍ អំណានអត្ថបទខ្លីៗ ការនិយាយ និងសំណេរប្រយោគខ្លីៗ។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ flood, North, East, South និង West
- ហ្វឺត ឬដីស និងក្តារខៀន
- ខ្សែអាត់សម្លេង CD ឬ VCD។

៣. ជំនាំបង្រៀន (Teaching process)

A. រៀនពាក្យ (Vocabulary)

ចូរមើលរូបភាព។ ស្តាប់ និងថាតាម។ Look at the pictures. Listen and repeat.

គ្រូ : - បង្ហាញរូបភាព ឬសរសេរពាក្យក្នុងប្រអប់នៅលើក្តារខៀន រួចអានឱ្យសិស្សស្តាប់ បន្ទាប់ឱ្យសិស្សថាតាម។

- បកប្រែពាក្យជាភាសាខ្មែរ bright= ទឹកជំនន់, North= ទិសខាងជើង East = ទិសខាងកើត, South = ទិសខាងត្បូង, West = ទិសខាងលិច។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក។ Spell each word in the box with your partner.

គ្រូ : ឱ្យសិស្សម្តងពីរនាក់ៗដើម្បីប្រកបពាក្យ។ *ឧទាហរណ៍ ៖* សិស្សម្នាក់ (A) និយាយថា Please spell the word flood. ហើយម្នាក់ទៀត (B) ថា flood I spell f-l-o-o-d។

C. ការសន្ទនា (Conversation)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានសន្ទនាឱ្យសិស្សស្តាប់

- ឱ្យសិស្សពីរនាក់ម្តងៗសន្ទនាគ្នា។ ឧទាហរណ៍ ៖

Dara: Hi Rina! Did you sleep well last night?
Rina: Hi Dara! No. There was thunder.

២. ចូរស្តាប់ឡើងវិញ រួចសន្ទនាជាមួយដៃគូរបស់អ្នក។ Listen again and practice with your partner.

គ្រូ : - ឱ្យសិស្សសន្ទនាជាមួយដៃគូដោយប្រើឈ្មោះ និងសកម្មភាពផ្ទាល់ខ្លួន។

ឧទាហរណ៍ ៖ Hi _____! Did you sleep last night?
Hi _____! No. There was thunder.

D. វេយ្យាការណ៍ (Language Focus)

ចូរប្រើ “can” ជាមួយកិរិយាស័ព្ទនៅក្នុងប្រអប់ដើម្បីបំពេញប្រយោគ។ Use “can” with the verbs in the box to complete the sentences.

គ្រូ : - ឱ្យសិស្សចម្លងប្រយោគចូលក្នុងសៀវភៅសរសេរ បន្ទាប់ឱ្យបំពេញចន្លោះទំនេរដោយប្រើពាក្យក្នុងប្រអប់។

ឧទាហរណ៍៖ I can _____ the thunder. I can hear the thunder.

- ចម្លើយ៖ 1. see; 2. destroy; 3. hit; 4. sleep។

E. អំណាន (Reading)

១. ចូរស្តាប់ និងថាតាមគ្រូរបស់អ្នក។ Listen to your teacher and repeat.

គ្រូ : - អានឱ្យសិស្សស្តាប់ បន្ទាប់ឱ្យសិស្សថាតាម

- ពន្យល់ពាក្យពិបាកៗ ឬពាក្យថ្មី
- ឱ្យសិស្សម្នាក់អានអត្ថបទនិងម្នាក់ទៀតបកប្រែជាភាសាខ្មែរ។

២. ចូរសួរ និងឆ្លើយសំណួរ។ Ask and answer the questions.

គ្រូ : - ឱ្យសិស្សអានអត្ថបទស្ងាត់ៗរៀងៗខ្លួន បន្ទាប់មកឆ្លើយនឹងសំណួរ។ *ឧទាហរណ៍៖*

When do the floods in Cambodia start?
The floods in Cambodia start in August.

- ចម្លើយ ៖

1) The floods are heavy rain.
2) The floods are hitting the provinces in North West of Cambodia.
3) The floods destroy roads, houses, animals, farms and buildings.

F. ការនិយាយ (Speaking)

ចូរមើលរូបភាព បន្ទាប់ឆ្លើយនឹងសំណួរ ដោយប្រើ “can”។ Look at the pictures and answer the questions by using “can”.

គ្រូ : - ផ្តល់រូបភាពឱ្យសិស្សដើម្បីបង្ហាញ ដោយសួរមិត្តរួមថ្នាក់ពីអត្ថន័យរបស់រូបភាពទាំងនោះ។

- *ឧទាហរណ៍* ៖ សិស្សម្នាក់បង្ហាញរូបភាព rain ដោយសួរថា A: What can you see? ហើយសិស្សម្នាក់ទៀតឆ្លើយថា B: I can see the rain.

G. សំណេរ (Writing)

ចូរសរសេរឱ្យបានបួនប្រយោគអំពីសកម្មភាពរបស់អ្នកជាមួយនឹង I can _____ នៅក្នុងសៀវភៅសរសេររបស់អ្នក។ Write four sentences in your notebook about your activities with I can _____ ។

ឧទាហរណ៍ ៖ I can wash the dishes.

គួរចងចាំ (Remember)

គ្រូ : - បញ្ជាក់ប្រាប់សិស្សឱ្យចងចាំពាក្យ flood, ground, loud, sleep, North, East, South, West, hit, hear, see និង destroy។

- ប្រាប់ឱ្យសិស្សចងចាំពីរបៀបប្រើ “can” ជាមួយកិរិយាស័ព្ទ ដើម្បីបង្កើតប្រយោគសួរ What can you see? និងប្រយោគឆ្លើយ We can see the rainbow។

មេរៀនទី៥ : រំលឹកមេរៀនឡើងវិញ

Unit 5: Review

រយៈពេល ២ ម៉ោង

១. វត្ថុបំណង (Objective)

- អានពាក្យដែលមាននៅក្នុងប្រអប់ជាមួយនឹងគ្រូ
- បង្ហាញពីរបៀបប្រើ “ing” ជាមួយនឹងកិរិយាស័ព្ទ ដើម្បីឱ្យសិស្សអនុវត្ត
- បង្ហាញពីរបៀបប្រើ “can” ជាមួយនឹងកិរិយាស័ព្ទ ដើម្បីបំពេញចន្លោះទំនេរ
- បណ្តុះស្មារតីសិស្សឱ្យក្លាហានក្នុងការប្រកបពាក្យ និងសំណេរពាក្យនៅចន្លោះទំនេរ។

២. សម្ភារៈបង្រៀន (Teaching Materials)

- សៀវភៅសិស្ស និងសៀវភៅគ្រូ
- រូបភាព និងប័ណ្ណពាក្យដែលត្រូវនឹងពាក្យ thunder, rainy, rain, weather, bright, floods, dry និង sky
- ហ្វឺត ឬដីស និងក្តារខៀន
- ខ្សែអាត់សម្លេង CD ឬ VCD។

៣. ជំនាំបង្រៀន (Teaching process)

A. វេយ្យាករណ៍ (Language Focus)

១. ចូរស្តាប់ និងថាតាមពាក្យនៅក្នុងប្រអប់។ Listen and say the words in the box.

គ្រូ : - អានឱ្យសិស្សស្តាប់ បន្ទាប់ឱ្យសិស្សថាតាម។

- ឱ្យសិស្សបកប្រែពាក្យក្នុងតារាងជាភាសាខ្មែរ។

២. ចូរបន្ថែម “ing” លើកិរិយាស័ព្ទដែលមាននៅក្នុងប្រអប់ បន្ទាប់អនុវត្តជាមួយដៃគូរបស់អ្នក។ Add “ing” to the verbs in the box and practice with your partner.

គ្រូ : - ឱ្យសិស្សម្នាក់សួរ និងម្នាក់ទៀតឆ្លើយដោយប្រើ “ing”។

- *ឧទាហរណ៍៖* What are they doing? They are riding the bicycle to school.

៣. ចូរប្រើ “can” ជាមួយកិរិយាស័ព្ទនៅក្នុងប្រអប់ ដើម្បីបំពេញប្រយោគ។ Use “can” with the verbs in the box to complete the sentences.

គ្រូ : - ឱ្យសិស្សចម្លងប្រយោគចូលក្នុងសៀវភៅសរសេរ បន្ទាប់មកឱ្យសិស្សបំពេញចន្លោះទំនេរដោយប្រើពាក្យក្នុងប្រអប់។ *ឧទាហរណ៍* ៖ I can hear the thunder.

- ចម្លើយ ៖ 1. see; 2. destroy; 3. hit; 4. sleep។

B. ការប្រកបពាក្យ (Spelling)

ចូរប្រកបពាក្យនីមួយៗក្នុងប្រអប់ជាមួយដៃគូរបស់អ្នក។ Spell each word in the box with your partner.

គ្រូ : - ឱ្យសិស្សម្តងពីរនាក់ៗដើម្បីប្រកបពាក្យ។

- *ឧទាហរណ៍* ៖ សិស្សម្នាក់និយាយ (A) ថា Please spell the word dry. ហើយម្នាក់ទៀត (B) ថា dry I spell d-r-y។

C. **សំណេរ** (Writing)

ចូរបំពេញប្រយោគ ដោយប្រើពាក្យនៅក្នុងប្រអប់ ដើម្បីបំពេញចន្លោះទំនេរ។ Complete the sentences with the words in the box to the blanks.

គ្រូ : - ឱ្យសិស្សចម្លងប្រយោគចូលក្នុងសៀវភៅសរសេរ បន្ទាប់មកឱ្យបំពេញចន្លោះទំនេរដោយប្រើពាក្យ ក្នុងប្រអប់។ *ឧទាហរណ៍៖* The floods destroy the roads, buildings, farms and animals.

- ចម្លើយ ៖ 1. sky; 2. bright; 3. dry; 4. thunder; 5. rain; 6. weather; 7. rainy។